ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIFRS 11

## កិច្ចព្រមព្រៀងរួម
## Joint Arrangements

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# អារម្ភកថា

ដោយសារនយោបាយ **“ឈ្នះ-ឈ្នះ”** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា **“យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣”**, **“ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨”**, **“យុទ្ធសាស្ត្រត្រីកោណ”**, **“យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០”** និង **“យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨”** ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និង ក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី **“ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ”** ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" របស់រាជរដ្ឋា-ភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

៚៙៛

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ” នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន “*ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង “*ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម*” ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ងី តាយី**

## គោលបំណង

១ **គោលបំណង នៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុនេះ គឺដើម្បីបង្កើតគោលការណ៍ សម្រាប់ការរាយការណ៍ហិរញ្ញវត្ថុ ដោយបណ្តាអង្គភាពដែលមានភាគកម្មនៅក្នុងកិច្ចព្រមព្រៀងដែលត្រូវបានធ្វើអភិបាលភាពរួមគ្នា (មានន័យថា កិច្ចព្រមព្រៀងរួមទុន)។**

**គោលបំណង**

២ ដើម្បីសម្រេចគោលបំណង នៅក្នុងកថាខណ្ឌ ១ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ នេះកំណត់អត្ថន័យនៃពាក្យ *អភិបាលរួមគ្នា* និងតម្រូវឲ្យអង្គភាពដែលជាភាគីនៅក្នុងកិច្ចព្រមព្រៀងរួមកំណត់អំពីប្រភេទ នៃកិច្ចព្រមព្រៀងរួមទុន ដែលនៅក្នុងនោះវាត្រូវបានពាក់ព័ន្ធ ដោយការវាយតម្លៃសិទ្ធិ និងកាតព្វកិច្ចរបស់វា ហើយត្រូវកំណត់សិទ្ធិនិង

## គ្រប់ខណ្ឌកំណត់

៣ **ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុនេះត្រូវអនុវត្តដោយគ្រប់អង្គភាព ដែលជាភាគីនៅក្នុងកិច្ចព្រមព្រៀងរួម។**

## កិច្ចព្រមព្រៀងរួម

៤ **កិច្ចព្រមព្រៀងរួមគឺជាកិច្ចព្រមព្រៀងដែលភាគីពីរ ឬច្រើនមានអភិបាលភាពរួមគ្នា។**

៥ កិច្ចព្រមព្រៀងរួម មានចរិតលក្ខណៈដូចខាងក្រោមៈ

(ក) បណ្តាភាគីមានកាតព្វកិច្ចគោរពកិច្ចព្រមព្រៀងដែលបញ្ញតិ ដោយកិច្ចសន្យា(មើល កថាខណ្ឌ ខ២-ខ៤)។

(ខ) កិច្ចព្រមព្រៀងដែលបញ្ញតិដោយកិច្ចសន្យាផ្តល់ឲ្យភាគីពីរ ឬភាគីច្រើននូវអភិបាលភាពរួមគ្នានៃកិច្ចព្រមព្រៀងនោះ (មើល កថាខណ្ឌ ៧-១៣)។

៦ កិច្ចព្រមព្រៀងរួមគឺជាប្រតិបត្តិការរួមគ្នាឬការដាក់ទុនធ្វើអាជីវកម្មរួមគ្នា។

## អភិបាលភាពរួមគ្នា

**៧ អភិបាលភាពរួមគ្នាគឺជាការចែករំលែកដោយព្រមព្រៀងគ្នាដែលមានបញ្ញតិដោយកិច្ចសន្យា ដែលកើតឡើងតែ នៅពេលដែលការសម្រេចចិត្តអំពីសកម្មភាពពាក់ពន្ធ័តម្រូវឱ្យមានការព្រមព្រៀង ជាឯកច្ឆន្ទរបស់ភាគីដែលមានចំណែកអភិបាលភាព។**

៨ អង្គភាពដែលជាភាគីនៃកិច្ចព្រមព្រៀងត្រូវធ្វើការវាយតម្លៃថាតើ កិច្ចព្រមព្រៀង ដោយមានបញ្ញតិសន្យាផ្តល់ឱ្យភាគីទាំងអស់ ឬក្រុមមួយនៃភាគីទាំងអស់ធ្វើអភិបាលភាពលើកិច្ចព្រមព្រៀងរួមគ្នា។ ភាគីទាំងអស់ ឬក្រុមមួយនៃ ភាគីទាំងអស់ធ្វើអភិបាលភាពលើកិច្ចព្រមព្រៀងរួមគ្នា នៅពេលដែលពួកគេត្រូវធ្វើសកម្មភាពទាំងអស់គ្នាដើម្បីដឹក នាំសកម្មភាព ដែលមានផលប៉ះពាល់ជាដុំកំភួន លើប្រាក់ចំណេញ នៃកិច្ចព្រមព្រៀង (មានន័យថា សកម្មភាពពាក់ ពន្ធ័)។

៩ នៅពេលគេត្រូវកំណត់ថាភាគីទាំងអស់ ឬក្រុមមួយ នៃភាគីទាំងអស់ធ្វើអភិបាលភាពរួមគ្នាលើកិច្ចព្រៀង អភិបាលភាពរួមកើតឡើង តែនៅពេល

ដែលកាសម្រេចចិត្តអំពីសកម្មភាពពាក់ពន្ធ័តម្រូវឱ្យមានការយល់ស្របជាឯកច្ឆន្ទពីភាគីទាំងអស់ដែលធ្វើអភិបាលភាពរួមគ្នាលើកិច្ចព្រមព្រៀង។

១០ នៅក្នុងកិច្ចព្រមព្រៀងរួមគ្មានភាគីណាម្នាក់ធ្វើអភិបាលភាព លើកិច្ចព្រមព្រៀងតែម្នាក់ឯងនោះឡើយ។ ភាគីមួយនៃ អភិបាលភាពរួមគ្នា របស់កិច្ចព្រមព្រៀងមួយ អាចរារាំងភាគីមួយផ្សេងទៀត ឬក្រុមមួយនៃភាគីទាំងនោះពីការធ្វើ អភិបាលភាពលើកិច្ចព្រមព្រៀង។

១១ កិច្ចព្រមព្រៀង អាចជាកិច្ចព្រមព្រៀងរួម បើទោះបីជា មិនមែនភាគីទាំងអស់មានអភិបាលរួមគ្នា នៅក្នុងកិច្ចព្រមព្រៀងនោះ។ ស្តង់ដាររបាយ-ការណ៍ហិរញ្ញវត្ថុនេះញែកចេញពីគ្នាបណ្តាភាគីដែលមានអភិបាលភាពរួមគ្នានៃកិច្ចព្រមព្រៀងរួម (ប្រតិបត្តិកររួមគ្នា ឬអ្នកដាក់ទុនរួមគ្នា) និងបណ្តាភាគីដែលចូលរួម ប៉ុន្តែមិនមានអភិបាលភាពរួម នៅក្នុងកិច្ចព្រមព្រៀង រួម។

១២ អង្គភាពនឹងត្រូវប្រើការវិនិច្ឆ័យ នៅពេលវាយតម្លៃថាតើគ្រប់ភាគីទាំងអស់ ឬក្រុមមួយនៃភាគីទាំងនោះមានអភិបាលភាពរួម នៅក្នុងកិច្ចព្រមព្រៀងឬយ៉ាងណា។ អង្គភាព ត្រូវធ្វើការវាយតម្លៃ ដោយការពិចារណាវាល់ហេតុការណ៍និងកាលៈទេសៈ (មើល កថាខណ្ឌ ខ៥-ខ១១)។

១៣ ប្រសិនបើហេតុការណ៍ និងកាលៈទេសៈប្រែប្រួល អង្គភាព ត្រូវវាយតម្លៃឡើងវិញថាតើខ្លួនមានអភិបាលភាពរួម នៅក្នុងកិច្ចព្រមព្រៀងឬយ៉ាងណា។

## ប្រភេទនៃកិច្ចព្រមព្រៀងរួមគ្នា

**១៤ អង្គភាពត្រូវកំណត់ប្រភេទនៃកិច្ចព្រមព្រៀងរួមគ្នាដែលខ្លួនមានការពាក់ពន្ធ័។ ការបែងចែកប្រភេទនៃកិច្ចព្រមព្រៀង រួមគ្នា ថាជាប្រតិបត្តិកររួមគ្នា ឬ**

**ការដាក់ទុនរកស៊ីរួមគ្នាអាស្រ័យលើសិទ្ធិនិងកាតព្វកិច្ចរបស់បណ្ដាភាគីនៅក្នុងកិច្ច ព្រមព្រៀង។**

**១៥ ប្រតិបត្តិការរួមគ្នាគឺជាកិច្ចព្រមព្រៀងរួមគ្នាមួយដែលបណ្ដាភាគី ដែលមានអភិបាលភាពរួមគ្នានៃកិច្ចព្រមព្រៀងមានសិទ្ធិ លើទ្រព្យសកម្ម និងមានកាតព្វកិច្ចចំពោះបំណុល ដែលទាក់ទងនឹងកិច្ចព្រមព្រៀងនោះ។ បណ្ដាភាគីទាំងនោះត្រូវបានហៅថា ប្រតិបត្តិកររួម។**

**១៦ ការដាក់ទុនរួមគ្នា គឺជាកិច្ចព្រមព្រៀងមួយ ដែលបណ្ដាភាគី ដែលមានអភិបាលភាពរួមនៃកិច្ចព្រមព្រៀងមានសិទ្ធិទៅលើទ្រព្យសកម្មសុទ្ធរបស់កិច្ចព្រមព្រៀង។ បណ្ដាភាគីទាំងនោះហៅថា អ្នកវិនិយោគរួមទុន។**

១៧ អង្គភាព អនុវត្តការវិនិច្ឆ័យនៅពេលធ្វើការវាយតម្លៃថាតើកិច្ចព្រមព្រៀងរួមគ្នា គឺជាប្រតិបត្តិការរួមគ្នាឬជាការដាក់ទុនរកស៊ីរួមគ្នា។ អង្គភាព ត្រូវកំណត់ប្រភេទនៃកិច្ចព្រមព្រៀងរួម ដែលខ្លួនមានការពាក់ពន្ធ័ ដោយពិចារណាអំពី សិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនដែលបានមកពីកិច្ចព្រមព្រៀង។ អង្គភាពវាយតម្លៃសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនដោយពិចារណាអំពីរចនាសម្ពន្ធ័និងទម្រង់ច្បាប់របស់កិច្ចព្រមព្រៀង ពិចារណាលក្ខខណ្ឌ ដែលបានព្រមព្រៀងដោយបណ្ដាភាគីនៅក្នុងកិច្ចព្រមព្រៀង ដែលមានបញ្ញតិ នៃកិច្ចសន្យា និងនៅពេលមានភាពពាក់ពន្ធ័ពិចារណាកត្តានិងកាលៈទេសៈផ្សេងៗទៀត (មើល កថាខណ្ឌ ខ១២-ខ៣៣)។

១៨ ជួនកាល បណ្ដាភាគីទាំងអស់ត្រូវគោរពតាមកិច្ចព្រមព្រៀង ដែលមានធម្មនិយាម ដែលបានកំណត់ថាបណ្ដាភាគី បង្កើតនូវកិច្ចព្រមព្រៀងរួមគ្នាផ្សេងៗគ្នាដើម្បីដោះស្រាយសកម្មភាពជាក់លាក់មួយចំនួនដែលបង្កើតបានជាផ្នែក មួយនៃកិច្ចព្រមព្រៀង។ ទោះបីជាយ៉ាងណា កិច្ចព្រមព្រៀង

រួមគ្នាទាំងនោះទាក់ទងនឹង កិច្ចព្រមព្រៀង ដែលមានធម្មនិយាមដូចគ្នា ប្រភេទរបស់វាអាចខុសគ្នា ប្រសិនបើសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីខុសគ្នា នៅពេលអនុវត្តសកម្មភាពផ្សេងៗគ្នា ដែលពាក់ពន្ធ័នៅក្នុងកិច្ចព្រមព្រៀង ដែលមានធម្មនិយាម។ ជាផលវិបាក ប្រិតិបត្តិការរួមគ្នា និងការដាក់ទុនរួមគ្នាអាចបង្កើត ដំណាលគ្នានៅពេលដែលបណ្តាភាគីអនុវត្តសកម្មភាពខុសគ្នាដែលបង្កើតបានជាផ្នែកមួយនៃកិច្ចព្រមព្រៀង ដែលមានធម្មនិយាមដូចគ្នា។

១៩ ប្រសិនបើហេតុការណ៍ និងកាលៈទេសៈផ្លាស់ប្តូរ អង្គភាព ត្រូវវាយតម្លៃឡើងវិញថាតើ ប្រភេទនៃកិច្ចព្រមព្រៀងរួម គ្នាដែលខ្លួនមានការពាក់ពន្ធ័បានផ្លាស់ប្តូរឬយ៉ាងណា។

## របាយការណ៍ហិរញ្ញវត្ថុរបស់បណ្តាភាគីនៅក្នុងកិច្ចព្រមព្រៀងរួមគ្នា

### ប្រតិបត្តិការរួមគ្នា

២០ ប្រតិបត្តិកររួមគ្នានីមួយៗត្រូវទទួលស្គាល់ភាគកម្មរបស់ខ្លួន នៅក្នុងប្រតិបត្តិ-ការរួមគ្នាៈ

(ក) ទ្រព្យសកម្មរបស់ខ្លួន ដែលរួមមានចំណែកនៃទ្រព្យសកម្ម ដែលកាន់កាប់រួមគ្នា

(ខ) បំណុលរបស់ខ្លួន ដែលរួមមានចំណែកនៃបំណុលដែលកើតមានរួមគ្នា

(គ) ចំណូលដែលបានពីការលក់ទិន្នផលដែលបានមកពីប្រតិបត្តិការរួមគ្នាដែលជាចំណែករបស់ខ្លួន

(ឃ) **ចំណែកនៃចំណូលដែលបានមកពីការលក់ទិន្នផលដែលបានមកពីប្រតិបត្តិការរួមគ្នា និង**

(ង) **ចំណាយរបស់ខ្លួនដែលរួមមានទាំងចំណែកណាមួយនៃចំណាយដែលកើតឡើងរួមគ្នា។**

២១ ប្រតិបត្តិកររួមទុនគ្នាត្រូវរាប់បញ្ចូលនូវទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលពាក់ព័ន្ធនឹងភាគកម្មរបស់ខ្លួននៅក្នុងប្រតិបត្តិការរួមទុនដោយយោងតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិដែលអាចអនុវត្តបានទៅលើទ្រព្យសកម្ម បំណុល ចំណូល និងចំណាយជាក់លាក់មួយចំនួន។

២២ គណនេយ្យសម្រាប់ប្រតិបត្តិការ ដែលមានដូចជា ការលក់ ការដាក់ចូល ឬការទិញទ្រព្យសកម្មរវាងអង្គភាពជាមួយនឹងប្រតិបត្តិការរួមគ្នា ដែលនៅក្នុងនោះប្រតិបត្តិកររួមទុនត្រូវបានបញ្ជាក់នៅក្នុងកថាខណ្ឌខ៣៤-ខ៣៧។

២៣ ភាគីមួយដែលចូលរួម ប៉ុន្តែមិនមានអភិបាលភាពរួម នៅក្នុងប្រតិបត្តិការរួមគ្នាមួយ ត្រូវរាប់បញ្ចូលនូវភាគកម្មរបស់ខ្លួន នៅក្នុងកិច្ចព្រមព្រៀងដោយអនុលោមតាមកថាខណ្ឌ ២០-២២ ប្រសិនបើ ភាគីនោះមានសិទ្ធិទៅលើទ្រព្យសកម្មនោះនិងកាតព្វកិច្ចចំពោះបំណុល ដែលពាក់ពន្ធ័នឹងប្រតិបត្តិការរួម។ ប្រសិនបើភាគីមួយចូលរួម ប៉ុន្តែ មិនមានអភិបាលភាពរួមនៅក្នុងប្រតិបត្តិការរួមមិនមានសិទ្ធិទៅលើទ្រព្យសកម្មនោះនិងកាតព្វកិច្ចចំពោះបំណុលដែលពាក់ព័ន្ធនឹងប្រតិបត្តិការរួមនោះ ភាគីនោះត្រូវគណនាភាគកម្មរបស់ខ្លួននៅក្នុងប្រតិបត្តិការរួម ដោយអនុលោមតាម ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិដែលអាចអនុវត្តបានចំពោះភាគកម្មទាំងនោះ។

### ការដាក់ទុនរួមគ្នា

២៤ អ្នកវិនិយោគរួមទុនគ្នាត្រូវទទួលស្គាល់ភាគកម្មនៅក្នុងការរកស៊ីរួមទុនថាជាការវិនិយោគនិងត្រូវកំណត់ការវិនិយោគនោះដោយប្រើវិធីសាស្ត្រទ្រព្យកម្មសិទ្ធិ ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិ ២៨ *ការវិនិយោគ នៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធនិងក្រុមហ៊ុនរួមទុន* ដរាបណាអង្គភាពត្រូវបានលើកលែងពីការអនុវត្តន៍វិធិសាស្ត្រទ្រព្យកម្មសិទ្ធិដែលបានចែងនៅក្នុងស្តង់ដារ នោះ។

២៥ ភាគីមួយដែលចូលរួម ប៉ុន្តែមិនមានអភិបាលភាពរួម នៅក្នុងប្រតិបត្តិការរួមគ្នាមួយ ត្រូវរាប់បញ្ចូលនូវភាគកម្មរបស់ខ្លួន នៅក្នុងកិច្ចព្រមព្រៀងដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ *ឧបករណ៍ហិរញ្ញវត្ថុ* ដរាបណា ខ្លួនមានឥទ្ធិពលជាដុំកំភួនលើក្រុមហ៊ុនរួមទុនដែលក្នុងករណីនេះ ខ្លួនត្រូវគណនាវា ដោយអនុលោមតាម ស្តង់ដារគណនេយ្យអន្តរជាតិ ២៨ (ដូចដែលបានកែប្រែនៅ ឆ្នាំ២០១១)។

### របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក

២៦ នៅក្នុងរបាយការណ៍ដាច់ដោយឡែករបស់ខ្លួន ប្រតិបត្តិការរួមគ្នា ឬ អ្នកវិនិយោគរួមទុនគ្នាត្រូវគណនាភាគកម្មរបស់ខ្លួននៅក្នុងៈ

(ក) ប្រតិបត្តិការរួមគ្នាដោយអនុលោមតាម កថាខណ្ឌ ២០-២២

(ខ) ការដាក់ទុនរួមគ្នាដោយអនុលោមតាមកថាខណ្ឌ ១០ នៃស្តង់ដាគណនេយ្យអន្តរជាតិ២៧ *របាយការណ៍ដាច់ ដោយឡែក*។

២៧ នៅក្នុងរបាយការណ៍ដាច់ដោយឡែករបស់ខ្លួន ភាគីមួយដែលចូលរួម ប៉ុន្តែមិនមានអភិបាលភាពរួមគ្នា នៅក្នុងកិច្ចព្រមព្រៀងរួមទុន ត្រូវគណនាភាគកម្មរបស់ខ្លួននៅក្នុងៈ

(ក) ប្រតិបត្តិការរួមគ្នាដោយអនុលោមតាម កថាខណ្ឌ ២៣

(ខ) ការដាក់ទុនរួមគ្នាដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩, ដរាបណា អង្គភាពមានឥទ្ធិពលជាដុំកំភួនលើការវិនិយោគរួមទុន ដែលនៅក្នុងករណីនេះ ខ្លួនត្រូវអនុវត្តកថាខណ្ឌ ១០ នៃស្តង់ដារគណនេយ្យអន្តរជាតិ ២៧ (ដែលបានកែប្រែនៅឆ្នាំ២០១១)។

## ឧបសម្ពន្ធ័ ក

## ពាក្យបច្ចេកទេស

*ឧបសម្ពន្ធ័នេះគឺជាផ្នែកមួយនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ*

**កិច្ចព្រមព្រៀងរួមគ្នា** កិច្ចព្រមព្រៀងមួយដែលភាគីពីរឬច្រើននាក់មានអភិបាលភាពរួមគ្នា។

**អភិបាលភាពរួមគ្នា** ជាការចែករំលែកការធ្វើអភិបាលភាព លើកិច្ចព្រមព្រៀងមួយដោយមានការយល់ព្រមដោយបញ្ញត្តិដោយកិច្ចសន្យា ដែលកើតឡើងតែនៅពេលដែលការសម្រេចចិត្តអំពីសកម្មភាពពាក់ពន្ធ័តម្រូវឱ្យមានការយល់ព្រមជាឯកច្ឆ័ន្ទ។

**ប្រតិបត្តិការរួមគ្នា** កិច្ចព្រមព្រៀងរួមគ្នាដែលបណ្តាភាគី នានាមានអភិបាលភាពរួមគ្នានៅក្នុងកិច្ចព្រមព្រៀង មានសិទ្ធិ ចំពោះទ្រព្យ

សកម្ម និងកាតព្វកិច្ចសម្រាប់បំណុលពាក់ពន្ធ័នឹងកិច្ចព្រមព្រៀងនោះ។

| | |
|---|---|
| **ប្រតិបត្តិករួម** | ភាគីមួយនៃប្រតិបត្តិការរួមគ្នាដែលមានអភិបាលភាពរួមគ្នានៅក្នុងប្រតិបត្តិការរួមគ្នា។ |
| **ការដាក់ទុនរួមគ្នា** | កិច្ចព្រមព្រៀងរួមគ្នាដែលបណ្តាភាគីនានាមានអភិបាលភាពរួមគ្នានៅក្នុងកិច្ចព្រមព្រៀង មានសិទ្ធិចំពោះទ្រព្យសកម្មនៅក្នុងកិច្ចព្រមព្រៀងនោះ។ |
| **វិនិយោគិនរួមទុន** | ភាគីមួយនៃការដាក់ទុនរួមគ្នាដែលមានអភិបាលភាពរួមគ្នានៅក្នុងការដាក់ទុនរួមគ្នានោះ។ |
| **ភាគីនៅក្នុងកិច្ចព្រមព្រៀងរួម** | អង្គភាពដែលចូលរួមនៅក្នុងកិច្ចព្រមព្រៀងរួម ដោយមិនគិតដល់ថា តើអង្គភាពនោះមានអភិបាលភាពរួមនៅក្នុងកិច្ចព្រមព្រៀងឬយ៉ាងណាឡើយ។ |
| **យន្តការដាច់ដោយឡែក** | រចនាសម្ពន្ធ័ហិរញ្ញវត្ថុដាច់ដោយឡែកមួយ ដែលរួមមានបណ្តានីតិបុគ្គលដាច់ដោយឡែក ឬអង្គភាព ដែលបានទទួលស្គាល់ដោយច្បាប់ ដោយមិនគិតថា អង្គភាពទាំងនោះមានរូបវន្តបុគ្គល ឬអត់នោះឡើយ។ |

ពាក្យខាងក្រោមត្រូវបានឱ្យនិយមន័យនៅក្នុងស្តង់ដារគណនេយ្យអន្តរជាតិ ២៧ (បានកែប្រែនៅ ឆ្នាំ២០១១), ស្តង់ដារគណនេយ្យអន្តរជាតិ ២៨ (បានកែប្រែនៅ ឆ្នាំ២០១១) ឬស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ *របាយការណ៍ហិរញ្ញវត្ថុសមាស* និងត្រូវបានប្រើនៅក្នុងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុនេះ ដោយមានអត្ថន័យជាក់លាក់នៅក្នុងស្តង់ដារទាំងរបាយការណ៍ហិរញ្ញវត្ថុទាំងនោះ÷

- អភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគ
- វិធីសាស្ត្រទ្រព្យកម្មសិទ្ធិ
- អំណាច
- សិទ្ធិដែលមានការការពារ
- សកម្មភាពពាក់ពន្ធ័
- របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក
- ឥទ្ធិពលជាដុំកំភួន។

**ឧបសម្ពន្ធ័ ខ**

**សេចក្តីណែនាំសម្រាប់ការអនុវត្តន៍**

*ឧបសម្ពន្ធ័នេះ គឺជាផ្នែកមួយនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។ វាបរិយាយអំពីការអនុវត្តន៍ កថាខណ្ឌ ១-២៧ និងមានអំណាចដូចគ្នានឹងផ្នែកផ្សេងទៀតនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។*

ខ១ ឧទាហរណ៍នៅក្នុងឧបសម្ពន្ធ័គូសបញ្ជាក់អំពីស្ថានភាពដែលជាសម្មតិកម្ម។ បើទោះបីជា ទិដ្ឋភាពនៃឧទាហរណ៍ ខ្លះអាចត្រូវបានបង្ហាញ តាមបែបគំរូជាក់ស្តែងក៏ដោយ រាល់ហេតុការណ៍ពាក់ពន្ធ័នៃគំរូហេតុការណ៍ជាក់លាក់

មួយនឹងត្រូវបានវាយតម្លៃនៅពេលអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

## កិច្ចព្រមព្រៀងរួមគ្នា

### កិច្ចព្រមព្រៀងដោយបញ្ញត្តិដោយកិច្ចសន្យា (កថាខណ្ឌ ៥)

១២ កិច្ចព្រមព្រៀងដោយបញ្ញត្តិដោយកិច្ចសន្យាអាចត្រូវបានបង្ហាញ តាមវិធីជាច្រើន។ កិច្ចព្រមព្រៀងដោយបញ្ញត្តិដោយកិច្ចសន្យាដែលអាចអនុវត្តបានជាញឹកញាប់ ប៉ុន្តែមិនមែនជានិច្ចកាល ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដែលជាធម្មតា មានទម្រង់ជាកុងត្រា ឬ ចងក្រងជាឯកសារ អំពីការពិភាក្សារវាងភាគីនានា។យន្តការដែលមានបញ្ញត្តិដោយច្បាប់អាច បង្កើតនូវកិច្ចព្រមព្រៀងដែលអាចអនុវត្តបានដោយខ្លួនឯងផ្ទាល់ ឬ ដោយការរួមផ្សំជាមួយកុងត្រានានាជាមួយបណ្តាភាគីនានា។

១៣ នៅពេលដែល កិច្ចព្រមព្រៀងរួម ត្រូវបានបង្កើតឡើងតាមរយៈយន្តការដាច់ដោយឡែកមួយ (មើលកថាខណ្ឌ ១១៩-១៣៣) កិច្ចព្រមព្រៀងដោយមានបញ្ញត្តិដោយកិច្ចសន្យា ឬ ទិដ្ឋភាពមួយចំនួននៃកិច្ចព្រមព្រៀងដោយមានបញ្ញត្តិដោយកិច្ចសន្យា ដែលក្នុងករណីខ្លះនឹងត្រូវបានដាក់បញ្ចូលទៅក្នុងមាត្រានានា លក្ខន្តិក ឬទេសបញ្ញត្តិរបស់យន្តការដាច់ដោយឡែកនោះ។

*១៤ កិច្ចព្រមព្រៀងដោយមានបញ្ញត្តិដោយកិច្ចសន្យាកំណត់អំពីលក្ខខណ្ឌដែលបណ្តាភាគីចូលរួមក្នុងសកម្មភាពដែលជាកម្មវត្ថុនៃកិច្ចព្រមព្រៀង។ជាទូទៅកិច្ចព្រមព្រៀងដោយមានបញ្ញត្តិដោយកិច្ចសន្យាទាក់ទងនឹងបញ្ហា ដូចជាៈ*

(ក) គោលបំណង, សកម្មភាព, និងរយៈពេលនៃកិច្ចព្រមព្រៀងរួម
(ខ) របៀបនៃការតែងតាំងសមាជិកក្រុមប្រឹក្សានាយក ឬក្រុមប្រឹក្សាភិបាលរបស់កិច្ចព្រមព្រៀងរួម។
(គ) របៀបនៃការធ្វើការសម្រេចចិត្តៈ បណ្តាបញ្ហាដែលតម្រូវឱ្យមានការសម្រេចចិត្តពីភាគីនានា,សិទ្ធិបោះឆ្នោតរបស់ភាគីនានា, និងកម្រិតនៃការគាំទ្រដែលចាំបាច់សម្រាប់បញ្ហាទាំងនោះ។ ដំណើការនៃការសម្រេចចិត្ត ដែលបានឆ្លុះបញ្ចាំង នៅក្នុងកិច្ចព្រមព្រៀងដោយមានបញ្ញត្តិដោយកិច្ចសន្យា បង្កើតនូវអភិបាលភាព រួមគ្នានៃកិច្ចព្រមព្រៀង (មើល កថាខណ្ឌ ខ៥-ខ១១)។
(ឃ) ដើមទុនឬការដាក់ទុនដែលចាំបាច់របស់ភាគីនានា។
(ង) របៀបដែលភាគីត្រូវបែងចែក ទ្រព្យសកម្ម បំណុល ចំណូលចំណាយ ឬប្រាក់ចំណេញឬការខាតបង់ទាក់ទង នឹងកិច្ចព្រមព្រៀងរួមនោះ។

### អភិបាលភាពរួមគ្នា(កថាខណ្ឌ ៧-១៣)

ខ៥ នៅក្នុងការវាយតម្លៃថាតើ អង្គភាពមានអភិបាលភាពរួមគ្នា នៅក្នុងកិច្ចព្រមព្រៀងរួម ឬយ៉ាងណា អង្គភាព ត្រូវវាយតម្លៃជាដំបូងថា តើបណ្តាភាគីទាំងអស់ ឬ ក្រុមនៃភាគីធ្វើអភិបាលភាពលើកិច្ចព្រមព្រៀង ឬយ៉ាងណា។ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ កំណត់អត្ថន័យអំពីអភិបាលភាព និងត្រូវបានប្រើដើម្បីកំណត់ថាតើ ភាគីទាំងអស់ ឬក្រុមនៃភាគីត្រូវប្រឈមនឹង ឬមានសិទ្ធិចំពោះផលចំណេញអថេរ ដែលបានមកពីការពាក់ពន្ធ័ របស់ពួកគេជាមួយនឹងកិច្ចព្រមព្រៀងនិងមានលទ្ធភាពធ្វើឱ្យមាន

ឥទ្ធិពលដល់ប្រាក់ចំណេញទាំងនោះ តាមរយៈអំណាចរបស់ពួកគេ លើកិច្ចព្រមព្រៀងនោះ។ នៅពេលដែល ភាគីទាំងអស់ឬក្រុមនៃភាគី គិតជារួមមានលទ្ធភាពដឹកនាំសកម្មភាពដែលមានផលប៉ះពាល់ដល់ប្រាក់ចំណេញរបស់កិច្ចព្រមព្រៀង (មានន័យថា សកម្មភាពពាក់ពន្ធ័), ភាគីទាំងនោះធ្វើអភិបាលភាពរួមគ្នាលើកិច្ចព្រមព្រៀង។

១៦ បន្ទាប់ពីសន្និដ្ឋានថា គ្រប់ភាគីទាំងអស់ ឬក្រុមនៃភាគីធ្វើអភិបាលភាពលើកិច្ចព្រមព្រៀងទាំងអស់គ្នា, អង្គភាពត្រូវវាយតម្លៃថាតើខ្លួនមានអភិបាលភាពរួមនៅក្នុងកិច្ចព្រមព្រៀងឬយ៉ាងណា។ អភិបាលភាពរួមកើតឡើងតែនៅពេលដែលការសម្រេចចិត្តអំពីសកម្មភាពពាក់ពន្ធ័តម្រូវឱ្យមានការយល់ព្រមជាឯកច្ឆន្ទ័ពីភាគីនានាដែលធ្វើអភិបាលរួមគ្នា លើកិច្ចព្រមព្រៀងនោះ។អង្គភាពត្រូវធ្វើការវាយតម្លៃថាតើកិច្ចព្រមព្រៀងនោះ ត្រូវបានធ្វើអភិបាលភាពរួមគ្នាដោយភាគីទាំងអស់ ឬដោយក្រុមនៃភាគី, ឬត្រូវបានធ្វើអភិបាលដោយភាគីម្នាក់នៃបណ្តាភាគីទាំងអស់, អាចតម្រូវ ឱ្យមានការវិនិច្ឆ័យ។

១៧ ជួនកាល ដំណើការនៃការសម្រេចចិត្តដែលត្រូវបានយល់ព្រមដោយបណ្តាភាគីនៅក្នុងកិច្ចព្រមព្រៀងរួមនាំឲ្យមានការធ្វើអភិបាលភាពដោយវាទរហិត។ ឧទាហរណ៍ សន្មត់ថា ភាគីពីរបង្កើតកិច្ចព្រមព្រៀងមួយ ដែលនៅក្នុងនោះភាគីនិមួយៗមាន៥០ភាគរយនៃសិទ្ធិបោះឆ្នោត ហើយកិច្ចព្រមព្រៀងដោយមានបញ្ញតិដោយកិច្ចសន្យារវាងពួកគេបញ្ជាក់ថា យ៉ាងហោចណាស់ ៥១ភាគរយ នៃសិទ្ធិបោះឆ្នោត ត្រូវបានតម្រូវឱ្យធ្វើការសម្រេចចិត្តអំពីសកម្មភាពពាក់ពន្ធ័។ នៅក្នុងករណីនេះ បណ្តាភាគីបានយល់ព្រម ដោយវាទរហិតថា ពួកគេមានអភិបាលភាពរួមគ្នានៅ ក្នុងកិច្ចព្រមព្រៀង ដោយ

សារតែការសម្រេចចិត្តអំពីសកម្មភាពពាក់ពន្ធ័មិនអាចត្រូវបានធ្វើដោយមិនមានភាគីទាំង ពីយល់ព្រមឡើយ។

១៨ នៅក្នុងកាលៈទេសៈផ្សេងទៀត កិច្ចព្រមព្រៀងដោយមានបញ្ញត្តិ ដោយកិច្ចសន្យាតម្រូវឱ្យមានសមាមាត្រអប្បរមា នៃសិទ្ធិបោះឆ្នោត ដើម្បីធ្វើការសម្រេចចិត្ត លើសកម្មភាពពាក់ពន្ធ័។ នៅពេលដែលសមាមាត្រអប្បរមាដែលបានតម្រូវនៃសិទ្ធិបោះឆ្នោតអាចត្រូវបានសម្រេច ដោយការគួបផ្សំច្រើនជាងមួយ ដោយភាគីដែលបានយល់ព្រមទាំងអស់ កិច្ចព្រមព្រៀងនោះមិនមែនជាកិច្ចព្រមព្រៀងរួមគ្នាទេ ដរាបណាកិច្ចព្រមព្រៀង ដោយមានបញ្ញត្តិដោយកិច្ចសន្យាបញ្ជាក់ថាភាគីណាមួយ (ឬការគួបផ្សំជាមួយភាគីផ្សេងទៀត) ត្រូវបានតម្រូវឲ្យមានការយល់ព្រមជា ឯកច្ឆ័ន្ទចំពោះសកម្មភាពពាក់ពន្ធ័។

| ឧទាហរណ៍ |
| --- |
| **ឧទាហរណ៍ ១**<br><br>សន្មត់ថា មានបីភាគីបង្កើតកិច្ចព្រមព្រៀងមួយៈ ភាគី ក មាន ៥០ភាគរយ នៃសិទ្ធិបោះឆ្នោតនៅក្នុងកិច្ចព្រមព្រៀង, ភាគី ខ មាន៣០ភាគរយ និងភាគី គ មាន ២០ភាគរយ។ កិច្ចព្រមព្រៀងដោយមានបញ្ញត្តិដោយកិច្ចសន្យារវាងភាគី ក ភាគី ខ និងភាគី គ ចែងថា យ៉ាងតិចណាស់ ៧៥ភាគរយ នៃសិទ្ធិបោះឆ្នោតត្រូវការជាចាំបាច់ សម្រាប់ការធ្វើការសម្រេចចិត្ត អំពីសកម្មភាពពាក់ពន្ធ័របស់កិច្ចព្រមព្រៀង។ ទោះបីជា ភាគី ក អាចរាំងខ្ទប់ការសម្រេចចិត្តណាមួយក៏ដោយក៏ភាគី ក មិនធ្វើអភិបាលភាពលើកិច្ចព្រមព្រៀងដែរ ពីព្រោះគាត់ត្រូវការនូវការយល់ព្រមពីភាគី ខ។ លក្ខខណ្ឌនៃកិច្ចព្រមព្រៀងដោយមានបញ្ញត្តិដោយ |

កិច្ចសន្យាតម្រូវឱ្យមាន៧៥ភាគរយនៃសិទ្ធិបោះឆ្នោតដើម្បីធ្វើការសម្រេចចិត្តអំពីសកម្មភាពពាក់ពន្ធ័ ដែលមានន័យថា ភាគី ក និងភាគី ខ មានអភិបាលភាពរួមគ្នានៅក្នុងកិច្ចព្រមព្រៀង ពីព្រោះការសម្រេចចិត្តលើសកម្មភាពពាក់ពន្ធ័របស់កិច្ចព្រមព្រៀងមិនអាចធ្វើឡើងបានដោយមិនមានការយល់ព្រមពីភាគី ក និងភាគី ខ បានឡើយ។

## ឧទាហរណ៍ ២

សន្មត់ថា កិច្ចព្រមព្រៀងមួយ មានបីភាគីៈ ភាគី ក មាន៥០ភាគរយ នៃសិទ្ធិបោះឆ្នោតនៅក្នុងកិច្ចព្រមព្រៀង ហើយភាគី ខ និង ភាគី គ មាន ២៥ភាគរយក្នុងម្នាក់ៗ។ កិច្ចព្រមព្រៀងដោយមានបញ្ញត្តិដោយកិច្ចសន្យារវាងភាគី ក ភាគី ខ និង ភាគី គ ចែងថាយ៉ាងតិច ៧៥ភាគរយ នៃសិទ្ធិបោះឆ្នោត ត្រូវការជាចាំបាច់សម្រាប់ការធ្វើការសម្រេចចិត្តអំពីសកម្មភាពពាក់ពន្ធ័របស់កិច្ចព្រមព្រៀង។ ទោះបីជាភាគី ក អាចរាំងខ្ទប់ការសម្រេចចិត្តណាមួយក៏ដោយ ក៏ ភាគី ក មិនធ្វើអភិបាលភាពលើកិច្ចព្រមព្រៀងដែរ ពីព្រោះ គាត់ត្រូវការនូវការយល់ព្រមពីភាគី ខ ឬ ភាគី គ។ នៅក្នុងឧទារហរណ៍នេះ ភាគី ក ភាគី ខ និង ភាគី គ មានអភិបាលភាពរួមគ្នាក្នុងកិច្ចព្រមព្រៀង។ ទោះជាយ៉ាងណា មានការគួបផ្សំច្រើនយ៉ាងពីភាគីទាំងនោះ ដែលអាចនាំឲ្យសម្រេចបាន៧៥ភាគរយនៃសិទ្ធិបោះឆ្នោត (មានន័យថា ការរួមគ្នារវាងភាគ ក និងភាគី ខ ឬភាគី ក និងភាគី គ។ នៅក្នុងស្ថានភាពបែបនេះ ដើម្បីបានក្លាយជា កិច្ចព្រមព្រៀងរួម, កិច្ចព្រមព្រៀងដោយមានបញ្ញត្តិដោយកិច្ចសន្យារវាងភាគីនានា ចាំបាច់ត្រូវចែងអំពីការគួបផ្សំ ដែលចាំបាច់របស់ភាគីទាំងនោះ ដើម្បីយល់ព្រមជាឯកច្ឆ័ន្ទលើការសម្រេចចិត្ត លើសកម្មភាពពាក់ពន្ធ័របស់កិច្ចព្រមព្រៀង។

**ឧទាហរណ៍ ៣**

សន្មត់ថា កិច្ចព្រមព្រៀងមួយដែលមានភាគី ក មាន៣៥ភាគរយ និងភាគី ខ មាន៣៥ភាគរយ នៃសិទ្ធិបោះឆ្នោតនៅក្នុង កិច្ចព្រមព្រៀងមួយ ហើយ ៣០ ភាគរយទៀតត្រូវបានកាន់កាប់ដោយភាគីផ្សេងៗទៀត។ ការសម្រេចចិត្តលើសកម្មភាពពាក់ពន្ធ័ តម្រូវឱ្យមានការយល់ព្រមដោយសំលេងឆ្នោតភាគច្រើន។ ភាគី ក និងភាគី ខ មានអភិបាលភាពរួមគ្នា នៅក្នុងកិច្ចព្រមព្រៀង តែក្នុងករណីដែលកិច្ចព្រមព្រៀងដោយមានបញ្ញតិដោយកិច្ចសន្យាចែងថា ការសម្រេចចិត្តលើសកម្មភាព ពាក់ពន្ធ័របស់កិច្ចព្រមព្រៀងតម្រូវឱ្យមានការយល់ព្រមពីភាគី ក និងភាគី ខ។

ខ៩ ការតម្រូវឱ្យមានការព្រមព្រៀងជាឯកច្ឆ័ន្ទ មានន័យថា ភាគីមួយ ដែលមានអភិបាលភាពរួមគ្នានៅក្នុងកិច្ចព្រមព្រៀងអាចរារាំងភាគីមួយផ្សេងទៀត ឬក្រុមនៃភាគី ពីការសម្រេចចិត្តជាឯកតោភាគី (លើសកម្មភាពពាក់ពន្ធ័) ដោយមិនមានការយល់ព្រមរបស់ខ្លួន។ ប្រសិនបើការតម្រូវ សម្រាប់ការយល់ព្រមជាឯកច្ឆ័ន្ទទាក់ទងតែនឹង ការសម្រេចចិត្តដែលផ្តល់ឱ្យភាគីមួយនូវសិទ្ធិដែលមានការការពារ និងមិនមែនជាការសម្រេចចិត្តលើសកម្មភាពពាក់ពន្ធ័របស់កិច្ចព្រមព្រៀងភាគីនោះមិនមែនជាភាគីដែលមានអភិបាលភាព រួមគ្នានៅក្នុងកិច្ចព្រមព្រៀងឡើយ។

ខ១០ កិច្ចព្រមព្រៀងដោយមានបញ្ញតិដោយកិច្ចសន្យាអាចរួមមានឃ្លាប្រយោគស្តីអំពីដំណោះស្រាយជំលោះ ដូចជា មជ្ឈត្តវិនិច្ឆ័យ។ ខមាត្រាទាំងនេះអាចអនុញ្ញាតិសម្រាប់ការសម្រេចចិត្តដែលត្រូវបានធ្វើឡើង នៅពេលមិនមានការយល់ព្រមជាឯកច្ឆ័ន្ទនៅក្នុងចំណោមភាគីដែលមានអភិបាលភាពរួម

គ្នា។ អត្ថិភាពនៃខមាត្រាទាំងនោះមិនរារាំងកិច្ចព្រមព្រៀង មិនឱ្យមានអភិបាលភាព រួមគ្នា និងកិច្ចព្រមព្រៀងរួម នោះឡើយ។




កិច្ចព្រមព្រៀងត្រូវបានធ្វើអភិបាលរួមគ្នា៖
កិច្ចព្រមព្រៀងគឺជាកិច្ចព្រមព្រៀងរួមទុន

ខ១១ នៅពេលដែល កិច្ចព្រមព្រៀងមួយនៅក្រៅក្របខណ្ឌ នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ អង្គភាពត្រូវរាប់បញ្ចូលភាគកម្មរបស់ខ្លួននៅក្នុងកិច្ចព្រមព្រៀងដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុដែលពាក់ពន្ធ័ ដូចជា ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០, ស្តង់ដារគណនេយ្យអន្តរជាតិ ២៨ (បានកែប្រែនៅឆ្នាំ២០១១) ឬស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩។

១១២ កិច្ចព្រមណព្រៀងរួមទុនត្រូវបានបង្កើតឡើងសម្រាប់គោលបំណងផ្សេងៗគ្នា (ឧ.វិធីដែលបណ្តាភាគីចែករំលែក ចំណាយឬហានិភ័យ, ឬជាវិធីដែលអនុញ្ញាតិឱ្យបណ្តាភាគីទទួលបានបច្ចេកវិទ្យាថ្មី ឬទីផ្សារថ្មី), និងអាចត្រូវបានបង្កើតឡើងដោយមានរចនាសម្ពន្ធ័និងទម្រង់ច្បាប់ខុសៗគ្នា។

១១៣ កិច្ចព្រមព្រៀងខ្លះមិនតម្រូវឲ្យមានសកម្មភាពដែលនឹងធ្វើឲ្យកិច្ចព្រមព្រៀងត្រូវបានអនុវត្តជាយន្តការដាច់ដោយឡែកឡើយ។ ក៏ប៉ុន្តែ មានកិច្ចព្រមព្រៀងផ្សេងទៀតពាក់ពន្ធ័នឹងការបង្កើតយន្តការដាច់ដោយឡែកមួយ។

១១៤ ការបែងចែកថ្នាក់ នៃកិច្ចព្រមព្រៀងរួម ដែលបានតម្រូវដោយស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ អាស្រ័យលើសិទ្ធិនិងកាតព្វកិច្ច របស់ភាគីដែលកើតចេញពីកិច្ចព្រមព្រៀង នៅក្នុងសកម្មភាពអាជីវកម្មធម្មតា។ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ នេះបែងចែកថ្នាក់ នៃកិច្ចព្រមព្រៀងរួម ថាជា ប្រតិបត្តិការរួមគ្នា ឬជាការវិនិយោគរួមទុនគ្នា។ នៅពេលដែលអង្គភាពមានសិទ្ធិទៅលើទ្រព្យសកម្ម និងមានកាតព្វកិច្ច ចំពោះបំណុលដែលទាក់ទងនឹង កិច្ចព្រមព្រៀង, កិច្ចព្រមព្រៀងនោះ គឺជាប្រតិបត្តិការរួម។ នៅពេលអង្គភាពមានសិទ្ធិលើទ្រព្យសកម្មសុទ្ធនៅក្នុងកិច្ចព្រមព្រៀង, កិច្ចព្រមព្រៀងនោះ គឺជាការវិនិយោគ រួមទុនគ្នា។ កថាខណ្ឌ ១១៦-ខ៣៣ កំណត់អំពីការវាយតម្លៃដែលអង្គភាពមួយអនុវត្តដើម្បីកំណត់ថា តើខ្លួនមានភាគកម្មនៅក្នុងប្រតិបត្តិការរួម ឬមានភាគកម្មនៅក្នុងការវិនិយោគរួមទុនគ្នា។

## ការបែងចែកថ្នាក់នៃកិច្ចព្រមព្រៀងរួម

១១៥ ដូចបានចែងនៅក្នុង កថាខណ្ឌ ១១៤, ការបែងចែកថ្នាក់ នៃកិច្ចព្រមព្រៀងរួមតម្រូវឱ្យគ្រប់ភាគីធ្វើការវាយតម្លៃលើសិទ្ធិនិងកាតព្វកិច្ច ដែលកើតចេញពីកិច្ចព្រមព្រៀង។នៅពេលធ្វើការវាយតម្លៃ អង្គភាពត្រូវពិចារណាដូចខាងក្រោម:

(ក) រចនាសម្ព័ន្ធនៃកិច្ចព្រមព្រៀងរួម(មើល កថាខណ្ឌ ១១៦ - ១២១)។

(ខ) នៅពេលណាដែលកិច្ចព្រមព្រៀងរួមត្រូវបានរៀបចំតាមរយៈយន្តការដាច់ដោយឡែកមួយ។

(១) ទម្រង់ផ្លូវច្បាប់របស់យន្តការដាច់ដោយឡែកនោះ (មើល កថាខណ្ឌ ១២២ - ១២៤)

(២) លក្ខខណ្ឌ នៃកិច្ចព្រមព្រៀង ដោយមានបញ្ញត្តិ ដោយកិច្ចសន្យា (មើល កថាខណ្ឌ ១២៥-១២៨) និង

(៣) នៅពេលដែលបាក់ពន្ធ័, ត្រូវពិចារណាហេតុការណ៍និងកាលៈទេសៈផ្សេងៗទៀត (កថាខណ្ឌ១២៩-១៣៣)។

## រចនាសម្ពន្ធ័របស់កិច្ចព្រមព្រៀងរួម

### *កិច្ចព្រមព្រៀងមិនបង្កើតឡើងតាមរយៈយន្តការដាច់ដោយឡែក*

១១៦ កិច្ចព្រមព្រៀងរួម ដែលមិនបង្កើតឡើងតាមរយៈយន្តការដាច់ដោយឡែកមួយគឺជាប្រតិបត្តិការរួម។ នៅក្នុងករណីនេះកិច្ចព្រមព្រៀងដោយមានបញ្ញតិដោយកិច្ចសន្យាបង្កើតឡើងនូវសិទ្ធិលើទ្រព្យសកម្មនិងកាតព្វកិច្ច

ចំពោះបំណុលរបស់បណ្ដាភាគីនៅក្នុងកិច្ចព្រមព្រៀង, ហើយសិទ្ធិរបស់បណ្ដាភាគីចំពោះចំណូលនិងចំណាយដែលមាន ការពាក់ពន្ធ័។

១១៧ កិច្ចព្រមព្រៀងដោយមានបញ្ញតិ ដោយកិច្ចសន្យា តែងតែបរិយាយអំពីចរិតលក្ខណៈ នៃសកម្មភាពដែលជាកម្មវត្ថុរបស់កិច្ចព្រមព្រៀង និងអំពីរបៀបដែលបណ្ដាភាគី មានបំណងអនុវត្តសកម្មភាពទាំងអស់នោះរួមគ្នា។ ឧទាហរណ៍ បណ្ដាភាគីនៅក្នុងកិច្ចព្រមព្រៀងមួយអាចយល់ព្រមផលិតផលិតផលមួយជាមួយគ្នា ដោយភាគីនីមួយៗទទួលខុសត្រូវ ចំពោះកិច្ចការដ៏ជាក់លាក់មួយ ហើយភាគីនីមួយៗប្រើប្រាស់ទ្រព្យសកម្មផ្ទាល់ខ្លួន និងបង្ករបំណុលផ្ទាល់ខ្លួន។កិច្ចព្រមព្រៀងដោយមានបញ្ញតិដោយកិច្ចសន្យាក៏អាចបញ្ជាក់អំពីរបៀបនៃការបែងចែកចំណូលនិងចំណាយ ចំពោះភាគីនិមួយៗ។នៅក្នុងករណីបែបនេះ សហប្រតិបត្តិករនីមួយៗ ទទួលស្គាល់នៅក្នុងរបាយការណ៍ ហិរញ្ញវត្ថុរបស់ខ្លួននូវទ្រព្យសកម្ម និងបំណុល ដែលបានប្រើចំពោះកិច្ចការដ៏ជាក់លាក់នោះ និងទទួលស្គាល់ចំណែកនៃចំណូល និងចំណាយរបស់ខ្លួនដោយអនុលោមតាមកិច្ចព្រមព្រៀងដោយមានបញ្ញតិ ដោយកិច្ចសន្យា។

១១៨ នៅក្នុងករណីផ្សេងទៀតបណ្ដាភាគីនៅក្នុងកិច្ចព្រមព្រៀងរួមអាចយល់ព្រម ជាឧទាហរណ៍ ចែករំលែកនិងប្រើប្រាស់ទ្រព្យសកម្មមួយជាមួយគ្នា។ នៅក្នុងករណីបែបនេះ កិច្ចព្រមព្រៀងដោយមានបញ្ញតិដោយកិច្ចសន្យាបង្កើតនូវសិទ្ធិរបស់ភាគីលើចំពោះទ្រព្យសកម្ម និងត្រូវប្រើប្រាស់រួមគ្នា និងបង្កើតឡើង នូវរបៀបនៃការបែងចែកទិន្នផល ឬចំណូល ដែលបានពីទ្រព្យសកម្ម និងរបៀបនៃការបែងចែកចំណាយ ប្រតិបត្តិការរវាងភាគីទាំងអស់។ សហប្រតិបត្តិករនីមួយៗកំណត់អំពីចំណែករបស់ខ្លួនលើទ្រព្យសកម្ម

រួមគ្នា និងបានយល់ព្រមលើការបែងចែកបំណុល, និងទទួលស្គាល់ចំណែកនៃទិន្នផល ចំណូល និងចំណាយដោយអនុលោមតាម កិច្ចព្រមព្រៀងដោយមានបញ្ញត្តិដោយកិច្ចសន្យា។

*កិច្ចព្រមព្រៀងរួមដែលបង្កើតឡើងតាមរយៈយន្តការដាច់ដោយឡែកមួយ*

១១៩ កិច្ចព្រមព្រៀងរួមដែលនៅក្នុងនោះទ្រព្យសកម្មនិងបំណុលទាក់ទងនឹងកិច្ចព្រមព្រៀងត្រូវបានកាន់កាប់នៅក្នុងយន្តការដាច់ដោយឡែកមួយ អាចជាការវិនិយោគរួមទុន ឬប្រតិបត្តិការរួម។

១២០ ភាគីមួយជាសហប្រតិបត្តិករ ឬជាវិនិយោគិនរួមទុន អាស្រ័យលើសិទ្ធិរបស់ភាគីទៅលើទ្រព្យសកម្ម និងកាតព្វកិច្ចចំពោះបំណុលទាក់ទងនឹងកិច្ចព្រមព្រៀង ដែលត្រូវបានកាន់កាប់នៅក្នុងយន្តការដាច់ដោយឡែកនោះ។

១២១ ដូចមានចែងនៅក្នុងកថាខណ្ឌ ១១៥, នៅពេលដែល ភាគីទាំងអស់រៀបចំបង្កើតកិច្ចព្រមព្រៀងរួម នៅក្នុងយន្តការដាច់ដោយឡែកមួយ, បណ្ដាភាគីទាំងនោះចាំបាច់ត្រូវ វាយតម្លៃទម្រង់ច្បាប់របស់អង្គដាច់ដោយឡែកនោះ លក្ខខណ្ឌនៅក្នុងកិច្ចព្រមព្រៀងដោយមានបញ្ញត្តិដោយកិច្ចសន្យា និង នៅពេលដែលពាក់ពន្ធ័ វាយតម្លៃហេតុការណ៍និងកាលៈទេសៈផ្សេងៗដែលផ្ដល់ឲ្យពួកគេនូវៈ

(ក) សិទ្ធិលើទ្រព្យសកម្ម និងកាតព្វកិច្ច ចំពោះបំណុលទាក់ទងនឹងកិច្ចព្រមព្រៀង(មានន័យថា កិច្ចព្រមព្រៀងគឺជាប្រតិបត្តិការរួមគ្នា) ឬ

(ខ) សិទ្ធិលើទ្រព្យសកម្មសុទ្ធរបស់កិច្ចព្រមព្រៀង (មានន័យថា កិច្ចព្រមព្រៀងគឺជា ការវិនិយោគរួមទុន)។

**ការបែងចែកថ្នាក់របស់កិច្ចព្រមព្រៀងរួមៈ ការវាយតម្លៃសិទ្ធិរបស់ភាគីនិងកាតព្វកិច្ចដែលកើតចេញពីកិច្ចព្រមព្រៀង**




## ទម្រង់ច្បាប់របស់យន្តការដាច់ដោយឡែក

ខ២២ ទម្រង់ច្បាប់របស់យន្តការដាច់ដោយឡែកមានភាពពាក់ពន្ធ័ នៅពេលដែលវាយតម្លៃប្រភេទនៃកិច្ចព្រមព្រៀង។ ទម្រង់ច្បាប់ជួយ ក្នុងការវាយតម្លៃលើកដំបូងអំពីសិទ្ធិរបស់ភាគីនានាលើទ្រព្យសកម្ម និងកាតព្វកិច្ច ចំពោះបំណុលដែលបានកាន់កាប់នៅក្នុងយន្តការដាច់ដោយឡែក ដូចជាថាតើបណ្តាភាគីដែលមានភាគកម្មនៅក្នុងទ្រព្យសកម្ម ដែលបានកាន់កាប់នៅក្នុងយន្តដាច់ដោយឡែក និងថាតើ ពួកគេទទួលខុសត្រូវ ចំពោះបំណុលដែលមាននៅក្នុង យន្តការដាច់ដោយឡែកឬយ៉ាងណា។

២២៣ ជាឧទាហរណ៍ បណ្ដាភាគីអាចធ្វើកិច្ចព្រមព្រៀង តាមរយៈយន្តការដាច់ដោយឡែកដែលមានទម្រង់ច្បាប់បណ្ដាលឲ្យយន្តការដាច់ដោយឡែកត្រូវបានពិចារណានៅក្នុងកម្រិតសិទ្ធិរបស់ខ្លួន (មានន័យថាទ្រព្យសកម្ម និងបំណុលដែលបានកាន់កាប់ នៅក្នុងយន្តការដាច់ដោយឡែក គឺជាទ្រព្យសកម្មនិងបំណុលរបស់យន្តការដាច់ដោយឡែកនិងមិនមែនជាទ្រព្យសកម្មនិងបំណុលរបស់បណ្ដាភាគីទាំងនោះឡើយ)។ នៅក្នុងករណីនេះ ការវាយតម្លៃលើសិទ្ធិនិងកាតព្វកិច្ចដែលបានប្រគល់ឲ្យដល់បណ្ដាភាគីដោយទម្រង់ច្បាប់ របស់យន្តការដាច់ដោយឡែកបង្ហាញថា កិច្ចព្រមព្រៀងគឺជាការវិនិយោគរួមទុន។ ទោះជាយ៉ាងណាក្ដី លក្ខខណ្ឌដែលបានព្រមព្រៀងដោយភាគីទាំងអស់ នៅក្នុងកិច្ចព្រមព្រៀងដោយមានបញ្ញត្តិ ដោយកិច្ចសន្យា (មើល កថាខណ្ឌ ខ២៥-ខ២៨) និង នៅពេលពាក់ពន្ធ័កត្តានិងកាលៈទេសៈផ្សេងទៀត (មើល កថាខណ្ឌខ២៩-ខ៣៣) អាចបដិសេធការវាយតម្លៃសិទ្ធិ និងកាតព្វកិច្ច ដែលបានប្រគល់ឲ្យបណ្ដាភាគី ដោយទម្រង់ច្បាប់របស់យន្តការដាច់ដោយឡែក។

ខ២៤ ការវាយតម្លៃ លើសិទ្ធិនិងកាតព្វកិច្ច ដែលបានប្រគល់ឲ្យភាគីទាំងអស់ដោយទម្រង់ច្បាប់របស់យន្តការដាច់ ដោយឡែកមានភាពគ្រប់គ្រាន់ ដើម្បីសន្និដ្ឋានថាកិច្ចព្រមព្រៀងគឺជាប្រតិបត្តិការរួម តែនៅក្នុងលក្ខខណ្ឌដែលភាគី ទាំងអស់ធ្វើកិច្ចព្រមព្រៀងរួមនៅក្នុងយន្តការដាច់ដោយឡែក ដែលទម្រង់ច្បាប់របស់វាមិនផ្ដល់ ឱ្យ នូវការបំបែកចេញពីគ្នារវាងភាគីទាំងអស់ជាមួយនឹងយន្តការដាច់ដោយឡែក (មានន័យថាទ្រព្យសកម្មនិងបំណុលបានកាន់កាប់ នៅក្នុងយន្តការដាច់ដោយឡែក គឺជាទ្រព្យសកម្ម និងបំណុលរបស់ភាគីទាំងអស់)។

## ការវាយតម្លៃលើលក្ខខណ្ឌរបស់កិច្ចព្រមព្រៀងដោយមានបញ្ញតិដោយកិច្ចសន្យា

១២៥ នៅក្នុងករណីជាច្រើន សិទ្ធិនិងកាតព្វកិច្ចដែលបានព្រមព្រៀង ដោយភាគីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងដោយមានបញ្ញតិ ដោយកិច្ចសន្យាមានសង្គតិភាព ឬមិនមានទំនាស់ ជាមួយនឹងសិទ្ធិនិងកាតព្វកិច្ច ដែលបានប្រគល់ឲ្យភាគីទាំងអស់ តាមទម្រង់ច្បាប់របស់យន្តការដាច់ដោយឡែកដែលនៅក្នុងនោះកិច្ចព្រមព្រៀងត្រូវបានបង្កើតឡើង។

១២៦ នៅក្នុងករណីផ្សេងទៀតភាគីទាំងអស់ប្រើកិច្ចព្រមព្រៀងដោយមានបញ្ញតិដោយកិច្ចសន្យាត្រូវធ្វើបញ្ជាក់ឬកែប្រែចំពោះសិទ្ធិ និងកាតព្វកិច្ច ដែលបានប្រគល់ឲ្យតាមទម្រង់ច្បាប់របស់យន្តការដាច់ដោយឡែកដែលនៅក្នុងនោះកិច្ចព្រមព្រៀងត្រូវបានបង្កើតឡើង។

| ឧទាហរណ៍ |
| --- |
| **ឧទាហរណ៍៤**<br><br>សន្មត់ថា មានភាគីពីរបង្កើតកិច្ចព្រមព្រៀងរួមនៅក្នុងក្រុមហ៊ុនសាជីវកម្ម។ ភាគីនីមួយៗមានកម្មសិទ្ធិភាព ៥០ភាគរយ នៅក្នុងក្រុមហ៊ុនសាជីវកម្ម។ លក្ខន្តិកៈអាចឲ្យមានការញែកចេញពីគ្នារវាងអង្គភាព និងម្ចាស់អាជីវកម្ម ដោយហេតុថា ទ្រព្យសកម្មនិងបំណុលដែលកាន់កាប់នៅក្នុងអង្គភាពគឺជាទ្រព្យសកម្មនិងបំណុលរបស់ក្រុមហ៊ុនសាជីវកម្មនោះ។ នៅក្នុងករណីបែបនេះ ការវាយតម្លៃសិទ្ធិ និងកាតព្វកិច្ចដែលបានប្រគល់ឲ្យតាមទម្រង់ច្បាប់របស់យន្តការដាច់ដោយឡែកបង្ហាញថា ភាគីទាំងអស់មានសិទ្ធិទៅលើទ្រព្យសកម្មសុទ្ធរបស់កិច្ចព្រមព្រៀង។ |

ទោះជាយ៉ាងណា ភាគីទាំងអស់កែប្រែចរិតលក្ខណៈរបស់ក្រុមហ៊ុនសាជីវកម្ម តាមរយៈកិច្ចព្រមព្រៀង ដោយមានបញ្ញតិ ដោយកិច្ចសន្យាដើម្បីឱ្យភាគីនីមួយៗមានភាគកម្ម នៅក្នុងទ្រព្យសកម្មរបស់ក្រុមហ៊ុនសាជីវកម្ម ហើយភាគីនីមួយៗទទួលខុសត្រូវលើបំណុលរបស់សាជីវកម្មតាមសមាមាត្រជាក់លាក់មួយ។ ការកែប្រែកិច្ចសន្យាទៅលើចរិតលក្ខណៈរបស់សាជីវកម្ម អាចបណ្តាលឲ្យកិច្ចព្រមព្រៀងក្លាយទៅជាប្រតិបត្តិការរួម។

ខ២៧ តារាងខាងក្រោមប្រៀបធៀបលក្ខខណ្ឌទូទៅនៅក្នុងកិច្ចព្រមព្រៀងដោយមានបញ្ញតិដោយកិច្ចសន្យារបស់ភាគីទាំងអស់ទៅនឹងប្រតិបត្តិការរួម និងប្រៀបធៀបលក្ខខណ្ឌទូទៅនៅក្នុងកិច្ចព្រមព្រៀងដោយមានបញ្ញតិដោយកិច្ចសន្យារបស់ភាគីទាំងអស់ទៅនឹងការវិនិយោគរួមទុន។ ឧទាហរណ៍នៃលក្ខខណ្ឌតាមកិច្ចសន្យាបានផ្តល់ឲ្យនៅក្នុងតារាងក្រោមមិនទូលំទូលាយនោះទេ។

| **ការវាយតម្លៃលក្ខខណ្ឌរបស់កិច្ចព្រមព្រៀងដោយមានបញ្ញតិដោយកិច្ចសន្យា** | | |
|---|---|---|
| | **ប្រតិបត្តិការរួម** | **ការវិនិយោគរួមទុន** |
| **លក្ខខណ្ឌរបស់កិច្ចព្រមព្រៀងដោយមានបញ្ញត្តិដោយកិច្ចសន្យា** | កិច្ចព្រមព្រៀង ដោយមានបញ្ញត្តិ ដោយកិច្ចសន្យាផ្តល់ឱ្យភាគីទាំងអស់ នៅក្នុងកិច្ចព្រមព្រៀងរួម នូវសិទ្ធិលើទ្រព្យសកម្ម និងកាតព្វកិច្ច | កិច្ចព្រមព្រៀងដោយមានបញ្ញតិដោយកិច្ចសន្យា ផ្តល់ឱ្យភាគីទាំងអស់ នៅក្នុងកិច្ចព្រមព្រៀងរួមនូវ សិទ្ធិលើទ្រព្យសកម្មសុទ្ធរបស់កិច្ចព្រមព្រៀង (មានន័យ |

| | | |
|---|---|---|
| | ចំពោះបំណុល ទាក់ទងនឹងកិច្ចព្រមព្រៀង។ | ថា វាជាយន្តការ ដាច់ដោយឡែក, មិនមែនជាភាគីទាំងអស់នោះទេ,ដែលមានសិទ្ធិលើទ្រព្យសកម្ម និង កាតព្វកិច្ចចំពោះបំណុល ទាក់ទងនឹងកិច្ចព្រមព្រៀង)។ |
| **សិទ្ធិលើទ្រព្យសកម្ម** | កិច្ចព្រមព្រៀង ដោយមានបញ្ញត្តិ ដោយ កិច្ចសន្យាកំណត់ថា ភាគីទាំងអស់ នៅក្នុងកិច្ចព្រមព្រៀងរួម បែងទាំងអស់នូវភាគកម្ម (សិទ្ធិ, សិទ្ធិទទួល ឬ កម្មសិទ្ធិភាព) លើទ្រព្យសកម្មទាក់ទងនឹងកិច្ចព្រមព្រៀងតាមសមាមាត្របានកំណត់(សមាមាត្រធៀបនឹងភាគកម្ម កម្មសិទ្ធិរបស់ភាគីទាំងអស់ នៅក្នុងកិច្ចព្រមព្រៀង ឬសមាមាត្រទៅនឹងសកម្មភាព ដែលបានអនុវត្ត តាមរយៈ កិច្ចព្រមព្រៀង ដែលបានបែងចែក | កិច្ចព្រមព្រៀងដោយមានបញ្ញត្តិដោយកិច្ចសន្យា កំនត់ថាទ្រព្យសកម្ម ដែលបានដាក់ចូលទៅក្នុងកិច្ចព្រមព្រៀង ឬបានទទួលនៅពេលបន្ទាប់មក ដោយកិច្ចព្រមព្រៀងរួមគឺជាទ្រព្យសកម្មរបស់កិច្ចព្រមព្រៀង។ ភាគីទាំងអស់ មិនមានភាគកម្ម (មានន័យថា មិនមានសិទ្ធិ សិទ្ធទទួលយក ឬកម្មសិទ្ធិ) លើទ្រព្យសកម្មដែលមាននៅក្នុងកិច្ចព្រមព្រៀង។ |

| | | |
|---|---|---|
| | ដោយផ្ទាល់ទៅឱ្យពួកគេ)។ | |
| **កាតព្វកិច្ចចំពោះបំណុល** | កិច្ចព្រមព្រៀងដោយមានបញ្ញតិដោយកិច្ចសន្យាកំណត់ថាភាគីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងរួម បែងទាំងអស់នូវបំណុល, កាតព្វកិច្ច, ថ្លៃដើម និងចំណាយ តាមសមាមាត្រដែលបានកំណតើកម្មសិទ្ធិភាព)លើទ្រព្យសកម្មទាក់ទងនឹង កិច្ចព្រមព្រៀងតាមសមាមាត្រ បានកំណត់ (សមាមាត្រ ធៀបនឹងភាគកម្ម កម្មសិទ្ធិរបស់ភាគីទាំង | កិច្ចព្រមព្រៀងដោយមានបញ្ញតិដោយកិច្ចសន្យា កំណត់ថាកិច្ចព្រមព្រៀងរួមត្រូវទទួលខុសត្រូវចំពោះបំណុលនិងកាតព្វកិច្ចនានារបស់កិច្ចព្រមព្រៀង។<br><br>កិច្ចព្រមព្រៀងដោយមានបញ្ញតិដោយ កិច្ចសន្យា កំណត់ថាបណ្តាភាគី នៅក្នុង កិច្ចព្រមព្រៀងត្រូវទទួលខុសត្រូវតែត្រឹមកម្រិតនៃការវិនិយោគរបស់ពួកគេ នៅក្នុងកិច្ចព្រមព្រៀង ឬទទួលខុសត្រូវ ត្រឹមកម្រិតនៃ |

| | | |
|---|---|---|
| | អស់នៅក្នុងកិច្ចព្រមព្រៀង ឬសមាមាត្រទៅនឹងសកម្មភាពដែលបានអនុវត្តតាមរយៈកិច្ចព្រមព្រៀង ដែលបានបែងចែក ដោយផ្ទាល់ទៅឲ្យពួកគេ)។ | កាតព្វកិច្ចដែលមិនទាន់បានទូទាត់ ឬត្រឹមកម្រិតទុនបន្ថែមដែលមាននៅក្នុងកិច្ចព្រមព្រៀង ឬទាំងពីរ។ |
| | កិច្ចព្រមព្រៀង ដោយមានបញ្ញត្តិ ដោយកិច្ចសន្យាកំណត់ថា បណ្ដាភាគី នៅក្នុងកិច្ចព្រមព្រៀង ត្រូវទទួលខុសត្រូវ ចំពោះចំណែកត្រូវទាមទារពីភាគីទីបី។ | កិច្ចព្រមព្រៀងដោយមានបញ្ញត្តិដោយកិច្ចសន្យាចែងថា ម្ចាស់បំណុល នៅក្នុងកិច្ចព្រមព្រៀងរួម មិនមានសិទ្ធិ លើវត្ថុបញ្ចាំដែល ដាក់ដោយភាគី ណាមួយសម្រាប់បំណុលឬកាតព្វកិច្ចនៅក្នុងកិច្ចព្រមព្រៀង។ |

| | | |
|---|---|---|
| **ចំណូល, ចំណាយ, ចំណេញ ឬខាត** | កិច្ចព្រមព្រៀង ដោយមានបញ្ញត្តិដោយកិច្ចសន្យាកំណត់ថាការបែងចែកចំណូល និងចំណាយផ្អែកលើលទ្ធផលរបស់ភាគីនិមួយៗ នៅក្នុងកិច្ចព្រមព្រៀងរួម។ឧទាហរណ៍ កិច្ចព្រមព្រៀងដោយមានបញ្ញត្តិ ដោយកិច្ចសន្យាអាចកំណត់ថា ចំណូលនិងចំណាយ ត្រូវបានបែងចែកដោយផ្អែកលើ សមត្ថភាពរបស់ភាគីនីមួយៗ ដែលប្រើនៅក្នុងរោងចក្រ ដែលប្រតិបត្តិការរួមគ្នា ដែលអាចខុសគ្នាពីភាគកម្ម នៃកម្មសិទ្ធិភាពនៅក្នុងកិច្ចព្រមព្រៀង រួម។ សម្រាប់ ករណីផ្សេងទៀត ភាគីទាំងអស់ អាចយល់ព្រមបែងចែកប្រាក់ចំណេញ ឬខាត ដែលទាក់ទងនឹង កិច្ចព្រមព្រៀង ដោយផ្អែកលើ | កិច្ចព្រមព្រៀងដោយមានបញ្ញត្តិដោយកិច្ចសន្យាកំណត់ថា ភាគីនីមួយៗ នៅក្នុងកិច្ចព្រមព្រៀងបែងចែកប្រាក់ចំណេញ ឬខាតដោយយោងតាមសកម្មភាព នៅក្នុងកិច្ចព្រមព្រៀង។ |

| | | |
|---|---|---|
| | សមាមាត្រកំណត់មួយ ដូចជា ភាគកម្មកម្មសិទ្ធិ របស់ភាគីនីមួយៗនៅក្នុងកិច្ចព្រមព្រៀង។ ប្រការនេះមិនរារាំងកិច្ចព្រមព្រៀងពីការធ្វើប្រតិបត្តិការរួមឡើយ ប្រសិនបើភាគីទាំងអស់ មានសិទ្ធិលើទ្រព្យសកម្ម និងកាតព្វកិច្ចចំពោះបំណុល ទាក់ទងនឹងកិច្ចព្រមព្រៀង។ | |

| | |
|---|---|
| **ការធានា** | បណ្តាភាគីនៅក្នុងកិច្ចព្រមព្រៀងរួមតែងតែតម្រូវឲ្យផ្តល់នូវការធានាចំពោះភាគីទីបី ជាឧទាហរណ៍ ទទួលសេវាកម្មពី ឬផ្តល់ហិរញ្ញប្បទាន ចំពោះកិច្ចព្រមព្រៀងរួម។ ខមាត្រានៃកិច្ចព្រមព្រៀង ឬការតាំងចិត្ត ដោយបណ្តាភាគី ដែលត្រូវផ្តល់ឲ្យពួកគេ, ដោយឯកឯង, មិនកំណត់ថា កិច្ចព្រមព្រៀងនោះ គឺជាប្រតិបត្តិការរួមឡើយ។ចរិតលក្ខណៈដែលកំណត់ថាតើ កិច្ចព្រមព្រៀងរួមគឺជាប្រតិប្តិការរួម ឬជាការវិនិយោគរួមទុន គឺថាតើភាគីទាំងអស់មានកាតព្វកិច្ចចំពោះបំណុលទាក់ទងនឹងកិច្ចព្រមព្រៀងឬយ៉ាងណា (ភាគីខ្លះអាច ឬមិនអាចផ្តល់នូវការធានាបានឡើយ)។ |

ខ២៨ កិច្ចព្រមព្រៀងដោយមានបញ្ញត្តិដោយកិច្ចសន្យាបញ្ជាក់ថាភាគីទាំងអស់មានសិទ្ធិលើទ្រព្យសកម្មនិងកាតព្វកិច្ចចំពោះបំណុលទាក់ទងនឹងកិច្ចព្រមព្រៀង, ពួកគេគឺជាបណ្តាភាគី នៅក្នុងប្រិតិបត្តិការរួមនិងមិនចាំបាច់ត្រូវពិចារណាកត្តានិងកាលៈទេសៈផ្សេងៗទៀតឡើយ(កថាខណ្ឌខ២៩-ខ៣៣) សម្រាប់គោលបំណងនៃការបែងចែកប្រភេទថ្នាក់នៃកិច្ចព្រមព្រៀងរួម។

## វាយតម្លៃកត្តានិងកាលៈទេសៈផ្សេងៗទៀត

ខ២៩ នៅពេលដែលលក្ខខណ្ឌ នៃកិច្ចព្រមព្រៀង ដោយមានបញ្ញត្តិ ដោយកិច្ចសន្យាមិនបញ្ជាក់ថាភាគីទាំងអស់មានសិទ្ធិទៅលើទ្រព្យសកម្ម និងមានកាតព្វកិច្ច ចំពោះបំណុលទាក់ទងនឹងកិច្ចព្រមព្រៀង, ភាគីទាំងអស់ត្រូវ

ពិចារណាកត្តា និងកាលៈទេសៈផ្សេងៗថាតើ កិច្ចព្រមព្រៀងនោះ គឺជាប្រតិបត្តិការរួមឬក៏ជាការវិនិយោគរួមទុន។

១៣០ កិច្ចព្រមព្រៀងរួមអាចត្រូវបានបង្កើតឡើង នៅក្នុងយន្តការដាច់ដោយឡែកមួយដែលតាមលក្ខណៈច្បាប់ផ្តល់ឲ្យ នូវការបំបែកចេញពីគ្នា រវាងភាគីទាំងអស់និងយន្តការដាច់ដោយឡែក។ លក្ខខណ្ឌតាមកិច្ចសន្យា ដែលបានយល់ព្រម នៅក្នុងចំណោមភាគីទាំងអស់ អាចមិនបញ្ជាក់អំពីសិទ្ធិរបស់ភាគីទាំងអស់លើទ្រព្យសកម្ម និងកាតព្វកិច្ចចំពោះបំណុល ដែលសូម្បីការពិចារណាអំពីកត្តានិងកាលៈទេសៈផ្សេងៗអាចនាំដល់កិច្ចព្រមព្រៀងបែបនោះត្រូវបានគេចាត់ថ្នាក់ថាជាប្រតិបត្តិការរួម។ នេះគឺជាករណីដែលនៅពេលដែលកត្តា និងកាលៈទេសៈផ្សេងទៀតផ្តល់ឲ្យភាគីទាំងអស់នូវសិទ្ធិចំពោះទ្រព្យសកម្ម និងកាតព្វកិច្ចចំពោះបំណុលទាក់ទងនឹងកិច្ចព្រមព្រៀង។

១៣១ នៅពេលដែលសកម្មភាព នៃកិច្ចព្រមព្រៀងត្រូវបានបង្កើតឡើង ជាចំបងសម្រាប់ការបម្រុងទុកនៃទិន្នផលចំពោះភាគីទាំងអស់ប្រការនេះបង្ហាញថាភាគីទាំងអស់មានសិទ្ធិយ៉ាងក្រាស់ក្រែល ចំពោះអត្ថប្រយោជន៍សេដ្ឋកិច្ចរបស់ទ្រព្យសកម្ម នៅក្នុងកិច្ចព្រមព្រៀង។ ភាគីទាំងអស់ នៅក្នុងកិច្ចព្រមព្រៀង តែងធានាបាននូវការទទួលបានទិន្នផល ដែលបានផ្តល់ឲ្យដោយកិច្ចព្រមព្រៀងតាមរយៈ នៃការរារាំងកិច្ចព្រមព្រៀង មិនឲ្យលក់ទិន្នផលទៅភាគីទីបី។

១៣២ ផលប៉ះពាល់នៃកិច្ចព្រមព្រៀងដែលមានការបង្កើតបែបនេះ ហើយគោលបំណងគឺថា បំណុលដែលកើតឡើង ដោយកិច្ចព្រមព្រៀង ត្រូវបានបំពេញដោយលំហូរសាច់ប្រាក់ដែលទទួលបានពីភាគីទាំងអស់តាមរយៈការទិញ

ទិន្នផលរបស់ពួកគេ។នៅពេលដែលភាគីទាំងអស់គឺជាប្រភពសាច់ប្រាក់តែមួយគត់ដែលរួមចំណែកនៅក្នុងនិរន្តរភាព របស់ប្រតិបត្តិការរបស់ កិច្ចព្រមព្រៀង ប្រការនេះបង្ហាញថា ភាគីទាំងអស់មានកាតព្វកិច្ច ចំពោះបំណុលទាក់ទងនឹងកិច្ចព្រមព្រៀង។

| ឧទាហរណ៍ |
|---|
| **ឧទាហរណ៍ ៥**<br><br>សន្មត់ថា ភាគីពីរបង្កើតកិច្ចព្រមព្រៀងរួមមួយនៅក្នុងក្រុមហ៊ុនសាជីវកម្មមួយ (អង្គភាព ៉ គ) ដែលនៅក្នុងនោះភាគីនិមួយៗមានកម្មសិទ្ធិភាព ៥០ភាគរយ។ គោលបំណងនៃកិច្ចព្រមព្រៀង គឺផលិតវត្ថុធាតុដែលត្រូវការចាំបាច់ដោយភាគីទាំងនោះសម្រាប់បម្រើសង្វាក់ផលិតកម្មរបស់ខ្លួនផ្ទាល់។ កិច្ចព្រមព្រៀងធានាថា ភាគីទាំងអស់ប្រើប្រាស់ឧបករណ៍ដែលផលិតនូវសំភារៈ ទៅតាមបរិមាណ និង គុណភាពរបស់ភាគីនិមួយៗ។<br><br>ទម្រង់ច្បាប់របស់អង្គភាព គ (ក្រុមហ៊ុនសាជីវកម្ម)ដែលតាមរយៈនោះសកម្មភាពដែលត្រូវបានអនុវត្ត បង្ហាញជាដំបូងថា ទ្រព្យសកម្មនិងបំណុល ដែលមាននៅក្នុងអង្គភាព គ គឺជាទ្រព្យសកម្មនិងបំណុលរបស់អង្គភាព គ។ កិច្ចព្រមព្រៀងដោយមានបញ្ញត្តិដោយកិច្ចសន្យារវាងភាគីទាំងអស់មិនបញ្ជាក់ថា ភាគីទាំងអស់មានសិទ្ធិលើទ្រព្យសកម្ម និងមានកាតព្វកិច្ច ចំពោះបំណុលរបស់អង្គភាព គ ឡើយ។ យោងតាមនោះ ទម្រង់ច្បាប់របស់អង្គភាព គ និងលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ដោយមានបញ្ញត្តិ ដោយកិច្ចសន្យាបង្ហាញថា កិច្ចព្រមព្រៀងគឺជាការវិនិយោគរួមទុន។ |

ទោះជាយ៉ាងណា ភាគីទាំងអស់ត្រូវពិចារណា នូវទិដ្ឋភាពនានារបស់កិច្ចព្រមព្រៀង ដូចខាងក្រោម៖

- ភាគីទាំងអស់យល់ព្រមទិញរាល់ទិន្នផលដែលផលិតបានដោយអង្គភាព គ តាមអត្រា ៥០ ទល់ ៥០។អង្គភាព គ មិនអាចលក់ទិន្នផលណាមួយទៅភាគីទីបីឡើយ ដរាបណាមានការយល់ព្រមពីភាគីទាំងពីរ នៅក្នុងកិច្ចព្រមព្រៀង។ ដោយសារតែគោលបំណងនៃកិច្ចព្រមព្រៀង គឺផ្តល់ឱ្យភាគទាំងអស់នូវទិន្នផលដែលត្រូវការការលក់ទៅឱ្យភាគីទីបីត្រូវបានរំពឹងថាមិនមានលក្ខណៈទូទៅ ហើយមិនមានសារៈសំខាន់ឡើយ។
- ថ្លៃរបស់ទិន្នផលដែលបានលក់ទៅឱ្យភាគីទាំងអស់ត្រូវបានកំណត់ដោយភាគីទាំងពីរតាមកម្រិតមួយ ដែលគ្របដណ្តប់បានចំណាយផលិតកម្ម និងចំណាយរដ្ឋបាលដែលកើតឡើងនៅក្នុងអង្គភាព គ ។ ផ្អែកលើម៉ូដែលនៃប្រតិបត្តិការនេះ កិច្ចព្រមព្រៀងមានបំណងធ្វើប្រតិបត្តិការត្រឹមកម្រិត នៃការស្រង់ដើមប៉ុណ្ណោះ។

ពីគម្រូហេតុការណ៍ខាងលើ កត្តានិងកាលៈទេសៈខាងក្រោមមានការពាក់ពន្ធ័៖

- កាតព្វកិច្ចរបស់ភាគីទាំងអស់ត្រូវទិញរាល់ទិន្នផលដែលបានផលិតដោយអង្គភាព គ ឆ្លុះបញ្ចាំងការពឹងអាស្រ័យទាំងស្រុងរបស់អង្គភាព គ លើភាគីទាំងអស់សម្រាប់ការបង្កើតលំហូរសាច់ប្រាក់ និង ដូច្នេះ ភាគីទាំងអស់មានកាតព្វកិច្ចផ្តល់មូលនិធិសម្រាប់ទូទាត់បំណុលរបស់អង្គភាព គ។
- ហេតុការណ៍ដែលភាគីទាំងអស់មានសិទ្ធិលើទិន្នផលដែលផលិតបានដោយអង្គភាព គ មានន័យថា ភាគីទាំងអស់កំពុងប្រើប្រាស់ហេតុដូច្នេះ ភាគីទាំងអស់មានសិទ្ធិចំពោះអត្ថប្រយោជន៍សេដ្ឋកិច្ចរបស់ទ្រព្យសកម្មរបស់

អង្គភាព **គ**។

ហេតុការណ៍និងកាលៈទេសៈទាំងនេះបង្ហាញថា កិច្ចព្រមព្រៀង គឺជាប្រតិបត្តិការរួម។ កាសន្និដ្ឋានអំពីប្រភេទនៃកិច្ចព្រម ព្រៀងនៅក្នុងកាលៈទេសៈទាំងនេះនឹងមិនមានការប្រែប្រួលទេប្រសិនបើ, ជំនួសឲ្យភាគីទាំងអស់ប្រើចំណែកនៃទិន្នផលរបស់ខ្លួនឯងផ្ទាល់នៅក្នុងដំណើរការនៃការផលិតជាបន្តបន្ទាប់, ភាគីទាំងអស់លក់ចំណែកនៃទិន្នផលរបស់ខ្លួនទៅឲ្យភាគីទីបី។

ប្រសិនបើ ភាគីទាំងអស់បានផ្លាស់ប្តូរលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ដោយមានបញ្ញត្តិដោយកិច្ចសន្យាដើម្បីឲ្យកិច្ចព្រមព្រៀងនោះអាចលក់ទិន្នផលទៅភាគីទីបី, ប្រការនេះ នឹងធ្វើឲ្យអង្គភាព គ ទទួលយកតម្រូវការ, មានសន្និធិ និងហានិភ័យឥណទាន។ នៅក្នុងសេណារីយូនេះ ការផ្លាស់ប្តូរនៅក្នុងហេតុការណ៍និងកាលៈទេសៈ នឹងតម្រូវឲ្យធ្វើការវាយតម្លៃប្រភេទ នៃកិច្ចព្រមព្រៀងរួម។ ហេតុការណ៍ និងកាលៈទេសៈ បែបនេះនឹងបង្ហាញថា កិច្ចព្រមព្រៀងគឺជាការវិនិយោគរួមទុន។

ខ៣៣ ក្រាហ្វិកខាងក្រោមឆ្លុះបញ្ចាំងអំពីការវាយតម្លៃអង្គភាពមួយ ដែលអនុវត្តតាមប្រភេទនៃកិច្ចព្រមព្រៀង នៅពេលដែលកិច្ចព្រមព្រៀងរួមត្រូវបានបង្កើតឡើងតាមរយៈយន្តការដាច់ដោយឡែកមួយ:

## ប្រភេទនៃកិច្ចព្រមព្រៀងរួមដែលបង្កើតឡើងតាមរយៈយន្តការដាច់ដោយឡែក




របាយការណ៍ហិរញ្ញវត្ថុរបស់បណ្តាភាគីនៅក្នុងកិច្ចព្រមព្រៀងរួម(កថាខណ្ឌ ២២)

**គណនេយ្យសម្រាប់ការលក់ទំនិញឬការរួមចំណែកនៃទ្រព្យសកម្មទៅក្នុងប្រតិបត្តិការរួម**

១៣៤ នៅពេលដែលអង្គភាពមួយមានប្រតិបត្តិការជាមួយប្រតិបត្តិការរួមគ្នា ដែលនៅក្នុងនោះ ខ្លួនគឺជាប្រតិបត្តិកររួម ដូចជា ចំណូលពីការលក់ទំនិញ ឬការចូលរួមចំណែកនៃទ្រព្យសកម្ម អង្គភាពកំពុងធ្វើប្រតិបត្តិការជាមួយភាគីដ៏ទៃ ទៀតនៅក្នុងប្រតិបត្តិការរួម និងប្រតិបត្តិកររួម ត្រូវទទួលស្គាល់ចំណេញឬខាតដែលកើតឡើងដោយប្រតិបត្តិការ បែបនោះត្រឹមកម្រិត នៃភាគកម្មរបស់ភាគីដ៏ទៃទៀតនៅក្នុងប្រតិបត្តិការរួមគ្នា។

១៣៥ នៅពេលដែលប្រតិបត្តិការផ្តល់នូវភស្តុតាងអំពីការថយចុះតម្លៃ អាចទទួលយកបានសុទ្ធរបស់ទ្រព្យសកម្មដែលត្រូវលក់ ឬដែលត្រូវដាក់ចូល នៅក្នុងប្រតិបត្តិការរួមគ្នា ឬការខាតបង់ដោយការធ្លាក់ចុះតម្លៃរបស់ទ្រព្យសកម្មទាំងនោះ, ការខាតបង់ទាំងនោះ ត្រូវទទួលស្គាល់ពេញលេញ ដោយប្រតិបត្តិកររួមគ្នា។

**គណនេយ្យសម្រាប់ការទិញទ្រព្យសកម្មពីកប្រតិបត្តិការរួមគ្នា**

១៣៦ នៅពេលដែលអង្គភាពមួយមានប្រតិបត្តិការជាមួយប្រតិបត្តិការរួមគ្នា ដែលនៅក្នុងនោះ ខ្លួនគឺជាប្រតិបត្តិកររួម សម្រាប់ការទិញទ្រព្យសកម្មបែបនេះ, អង្គភាពមិនត្រូវទទួលស្គាល់ចំណែកណាមួយនៃចំណេញឬខាតឡើយរហូតដល់ខ្លួនបានលក់ទ្រព្យសកម្មទាំងនោះទៅភាគីទីបី។

១៣៧ នៅពេលដែលប្រតិបត្តិការទាំងនោះផ្តល់នូវភស្តុតាងអំពីការធ្លាក់ចុះតម្លៃ អាចទទួលយកបានសុទ្ធរបស់ទ្រព្យសកម្ម ដែលត្រូវទិញ ឬដែលការខាតបង់ ដោយការធ្លាក់ចុះតម្លៃរបស់ទ្រព្យសកម្មទាំងនោះ, ប្រតិបត្តិកររួមត្រូវទទួលស្គាល់ ចំណែកនៃការខាតបង់ទាំងនោះដែលជារបស់ខ្លួន។

## ឧបសម្ព័ន្ធ គ

## កាលបរិច្ឆេទចូលជាធរមាន, អន្តរកាល, និងការដកចេញស្តង់ដារបាយការណ៍ហិរញ្ញវត្ថុផ្សេងៗ

*ឧបសម្ព័ន្ធនេះគឺជាផ្នែកមួយនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ និងមានសិទ្ធិអំណាចដូចគ្នានឹងផ្នែកផ្សេងទៀតនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។*

**កាលបរិច្ឆេទចូលជាធរមាន**

គ១ អង្គភាពត្រូវអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ សម្រាប់កាលបរិច្ឆេទនៅថ្ងៃទី១ ខែមករា ឬក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។ ការអនុវត្តន៍មុនត្រូវបានអនុញ្ញាត។ ប្រសិនបើ អង្គភាពអនុវត្តស្តង់ដារបាយការណ៍ ហិរញ្ញវត្ថុអន្តរជាតិនេះ មុនកាលបរិច្ឆេទខាងលើ អង្គភាពត្រូវលាតត្រដាងនូវហេតុការណ៍នោះ និងត្រូវអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០, ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១២ *ការលាតត្រដាងព័ត៌មាន* នៃភាគកម្មនៅក្នុងអង្គភាពផ្សេងៗ, ស្តង់ដាគណនេយ្យអន្តរជាតិ ២៧ (ដែលបានកែប្រែនៅឆ្នាំ២០១១) និងស្តង់ដាគណនេយ្យអន្តរជាតិ ២៨ (ដែលបានកែប្រែនៅ ឆ្នាំ២០១១) នៅពេលជាមួយគ្នា។

**អន្តរកាល**

**ការដាក់ទុនរួមគ្នា—អន្តរកាលពីការរួមបញ្ចូលជាផ្នែកទៅប្រើវិធីសាស្ត្រមូលធនផ្ទាល់**

គ២ នៅពេលផ្លាស់ប្តូរ ពីការរួមបញ្ចូលជាផ្នែក ទៅវិធីសាស្ត្រមូលធនផ្ទាល់, អង្គភាពត្រូវទទួលស្គាល់ការវិនិយោគរបស់ខ្លួន នៅក្នុងការវិនិយោគរួមទុននៅដើមការិយបរិច្ឆេទដំបូងបំផុតដែលបានបង្ហាញ។ ការវិនិយោគដំបូង

នោះត្រូវបានវាស់វែងថាជាបរិមាណសរុបនៃតម្លៃលើបញ្ជីរបស់ទ្រព្យសកម្ម និងបំណុល ដែលអង្គភាពមួយបានរួមបញ្ចូលជាផ្នែកៗពីមុន ដោយរួមមានទាំងមូលនិធិពាណិជ្ជកម្មដែលបានមកពីការទិញអង្គភាពអាជីវកម្ម។ ប្រសិនបើ ពីមុនមក មូលនិធិពាណិជ្ជកម្មជាកម្មសិទ្ធិរបស់អង្គបង្កើតសាច់ប្រាក់ដ៏ធំមួយ, ឬជាកម្មសិទ្ធិរបស់ក្រុ មនៃបណ្តាអង្គបង្កើតសាច់ប្រាក់, អង្គភាពត្រូវបែងចែកមូលនិធិពាណិជ្ជកម្មទៅការវិនិយោគរួមទុនដោយផ្អែកលើតម្លៃលើបញ្ជីរបស់ការ វិនិយោគរួមទុន និងអង្គបង្កើតសាច់ប្រាក់ ឬក្រុមនៃបណ្តាអង្គបង្កើតសាច់ប្រាក់ដែលមូលនិធិពាណិជ្ជកម្មស្ថិតនៅ។

គ៣ សមតុល្យដើមគ្រានៃការវិនិយោគដែលបានកំណត់ដោយអនុលោមតាមកថាខណ្ឌ គ២ ត្រូវចាត់ទុកថាជាចំណាយនៃការវិនិយោគនៅគ្រា នៃការទទួលស្គាល់លើកដំបូង។ អង្គភាពត្រូវអនុវត្តកថាខណ្ឌ ៤០-៤៣ នៃស្តង់ដាគណនេយ្យអន្តរជាតិ ២៨ (បានកែប្រែនៅ ឆ្នាំ២០១១) ចំពោះសមតុល្យដើមគ្រារបស់ការវិនិយោគដើម្បីវាយតម្លៃថាតើ ការវិនិយោគនោះមានការថយចុះតម្លៃ និងត្រូវទទួលស្គាល់នូវការខាតបង់ ដោយការថយចុះតម្លៃ ថាជាការកែ សម្រួលទៅនឹងប្រាក់ចំណេញរក្សាទុកនៅដើមគ្រានៃការិយបរិច្ឆេទដំបូងបំផុត ដែលបាននបង្ហាញ។ ការលើកលែងចំពោះការទទួលស្គាល់លើកដំបូងនៅក្នុងកថាខណ្ឌ ១៥ និងកថាខណ្ឌ ២៤ នៃស្តង់ដាគណនេយ្យអន្តរជាតិ ១២ *ពន្ធលើប្រាក់ចំណេញ* មិនអនុវត្តឡើយនៅពេល ដែលអង្គភាព ទទួលស្គាល់ការវិនិយោគមួយ នៅក្នុងការវិនិយោគរួមទុន ដែលកើតចេញពីការអនុវត្តការតម្រូវនានា នៅក្នុងដំណាក់កាលអន្តរកាលសម្រាប់ការវិនិយោគរួមទុន ដែលបានរួមបញ្ចូលជាផ្នែកៗកាលពីគ្រាកន្លងមក។

គ៤ ប្រសិនបើប្លូកសរុបរាល់ទ្រព្យសកម្មនិងបំណុល ដែលបានរួមបញ្ចូលជាផ្នែកៗកាលពីគ្រាកន្លងមក ធ្វើឲ្យមានទ្រព្យ សកម្មសុទ្ធអវិជ្ជមាន, អង្គភាពត្រូវវាយតម្លៃថាតើ កាតព្វកិច្ចតាមច្បាប់កំណត់ឬកាតព្វកិច្ចតាមគម្រោងដែលមានទាក់ទងនឹងទ្រព្យសកម្មសុទ្ធ ហើយប្រសិនបើមាន អង្គភាព ត្រូវទទួលស្គាល់បំផុលដែលមានការទាក់ទងនោះ។ ប្រសិនបើ អង្គភាពដឹងថាខ្លួនមិនមានការពាក់ពន្ធ័នឹងកាតព្វកិច្ចតាមច្បាប់កំណត់ ឬកាតព្វកិច្ចតាមគម្រោងដែលមានទាក់ទងនឹងទ្រព្យសកម្មសុទ្ធអវិជ្ជមាន, អង្គភាពមិនត្រូវទទួលស្គាល់បំណុលដែលពាក់ពន្ធ័ឡើយ ប៉ុន្តែអង្គភាព ត្រូវកែសម្រួលប្រាក់ចំណេញរក្សាទុកនៅដើមគ្រា នៃការិយបរិខច្ឆេទដំបូងបំផុត ដែលបានបង្ហាញ។ អង្គភាព ត្រូវលាតត្រដាងហេតុការណ៍នោះជាមួយនឹងចំណែកដែលមិនទទួលស្គាល់បង្គរនៃការខាតបង់នៅក្នុងការវិនិយោគរួមទុន នាកាលបរិច្ឆេទដើមគ្រានៃការិយបរិច្ឆេទដំបូងបំផុតដែលបានបង្ហាញ និងកាលបរិច្ឆេទដែលស្តង់ដា របាយការណ៍ អន្តរជាតិនេះត្រូវបានអនុវត្ត។

គ៥ អង្គភាពត្រូវលាតត្រដាងការបំបែកជាផ្នែកៗនៃទ្រព្យសកម្ម និងបំណុលដែលត្រូវបានរួមបញ្ចូលគ្នាទៅសមតុល្យនៃការវិនិយោគតែមួយគត់ នៅដើមគ្រានៃការិយបរិច្ឆទដំបូងបំផុតដែលបានបង្ហាញ។ ការលាតត្រដាងនោះត្រូវតែបានរៀបចំជាទម្រង់សរុបសម្រាប់ការវិនិយោគរួមទុន ដែលអង្គភាពអនុវត្តការតម្រូវអន្តរកាលដែលយោងទៅកថាខណ្ឌ គ២-គ៦។

គ៦ បន្ទាប់ពី ការទទួលស្គាល់លើកដំបូង អង្គភាពត្រូវគណនាការវិនិយោគរបស់ខ្លួននៅក្នុងការវិនិយោគរួមទុន ដោយប្រើវិធីសាស្ត្រមូលធនផ្ទាល់ដោយអនុលោមតាម ស្តង់ដារគណនេយ្យអន្តរជាតិ ២៨ (ដែលបានកែប្រែនៅឆ្នាំ២០១១)។

## ប្រតិបត្តិការរួមគ្នា-អន្តរកាលពីវិធីសាស្រ្តមូលធនផ្ទាល់ទៅការកត់ត្រាទ្រព្យសកម្ម និងបំណុល

គ៧ នៅពេលដែល មានការផ្លាស់ប្តូរពីវិធីសាស្រ្តមូលធនផ្ទាល់ទៅការកត់ត្រាទ្រព្យសកម្ម និងបំណុត្រាសម្រាប់ភាគកម្មនៅក្នុងការវិនិយោគរួមទុន, អង្គភាពត្រូវនៅដើមគ្រានៃការិយបរិច្ឆេទដំបូងបំផុតដែលបានបង្ហាញមិនទទួលស្គាល់នូវការវិនិយោគដែលត្រូវបានរាប់បញ្ចូល សម្រាប់ការប្រើវិធីសាស្រ្តមូលធនផ្ទាល់ និងធាតុផ្សេងទៀតដែល បង្កើតបានជាផ្នែកមួយនៃការវិនិយោគសុទ្ធ នៅក្នុងកិច្ចព្រមព្រៀង ដោយអនុលោម តាមកថាខណ្ឌ៣៨នៃស្តង់ដារ គណនេយ្យអន្តរជាតិ ២៨ (ដែលបានកែប្រែនៅឆ្នាំ២០១១) និងទទួលស្គាល់ចំណែករបស់ខ្លួននៅក្នុងទ្រព្យសកម្ម និងបំណុលដែលមាននៅក្នុងភាគកម្មនៅក្នុងប្រតិតបត្តិការរួមគ្នា ដោយរួមមានទាំងមូលនិធិពាណិជ្ជកម្មដែលអាច បង្កើតបានជាផ្នែកមួយនៃតម្លៃលើបញ្ជីរបស់ការវិនិយោគ។

គ៨ អង្គភាព ត្រូវកំណត់ភាគកម្មនៅក្នុងទ្រព្យសកម្ម និងបំណុលទាក់ទងនឹងប្រតិបត្តិការរួមគ្នាដោយផ្អែកលើសិទ្ធិនិងកាតព្វកិច្ចនៅក្នុងចំណែកជាក់លាក់មួយដោយអនុលោមតាមកិច្ចព្រមព្រៀងដោយមានបញ្ញត្តិដោយកិច្ចសន្យា។ អង្គភាពវាស់វែងតម្លៃលើបញ្ជីលើកដំបូងនៃទ្រព្យសកម្ម និងបំណុល ដោយការមិនប្រមូលផ្តុំមកពីតម្លៃលើបញ្ជីនៃការវិនិយោគ នៅដើមគ្រា នៃការិយបរិច្ឆេទដំបូងបំផុតដែលបានបង្ហាញ ដោយឈរលើព័ត៌មានដែលបានប្រើដោយ អង្គភាព ដែលអនុវត្តន៍វិធីសាស្រ្តមូលធនផ្ទាល់។

គ៩ ភាពខុសគ្នាណាមួយដែលកើតចេញពីការវិនិយោគ ដែលបានកំណត់ពីមុនដោយការប្រវិធីសាស្រ្តមូលធនផ្ទាល់រួម ជាមួយនឹងធាតុផ្សេងទៀតដែលបង្កើតបានជាការវិនិយោគសុរបរបស់អង្គភាពនៅក្នុងកិច្ចព្រមព្រៀងដោយអនុលោមតាម កថាខណ្ឌ ៣៨ នៃស្តង់ដាគណនេយ្យអន្តរជាតិ (ដែលបានកែប្រែនៅឆ្នាំ២០១១), និងបរិមាណសុទ្ធនៃទ្រព្យសកម្ម និងបំណុល ដោយរួមមានទាំងមូលនិធិពាណិជ្ជកម្ម ដែលបានទទួលស្គាល់ត្រូវតែៈ

(ក) កាត់កងគ្នាជាមួយនឹងមូលនិធិពាណិជ្ជកម្មទាក់ទងនឹងការវិនិយោគជាមួយនឹងភាពខុសគ្នានៅសល់ ដែលបានកែសម្រួលជាមួយនឹងប្រាក់ចំណេញរក្សាទុកនៅដើមគ្រានៃការិយបរិច្ឆេទដំបូងបំផុតដែលបានបង្ហាញ, ប្រសិនបើ បរិមាណសុទ្ធនៃទ្រព្យសកម្មនិងបំណុលដោយរួមមានទាំងមូលនិធិពាណិជ្ជកម្មនានាដែលបានទទួលស្គាល់ដែលមានតម្លៃខ្ពស់ជាងការវិនិយោគ (និងធាតុផ្សេងទៀត ដែលបង្កើតបានជាផ្នែកមួយនៃការវិនិយោគសុរប) មិនបានទទួលស្គាល់ឡើយ។

(ខ) កែសម្រួលជាមួយនឹងប្រាក់ចំណេញរក្សាទុកនៅដើមគ្រា នៃការិយ-បរិច្ឆេទដំបូងបំផុតដែលបានបង្ហាញ, ប្រសិនបើ បរិមាណសុទ្ធនៃទ្រព្យសកម្មនិងបំណុលដោយរួមមានទាំងមូលនិធិពាណិជ្ជកម្មនានាដែលបានទទួលស្គាល់ដែលមានតម្លៃទាបជាងការវិនិយោគ (និងធាតុផ្សេងទៀតដែលបង្កើតបានជាផ្នែកមួយនៃការវិនិយោគសុរប) មិនបានទទួលស្គាល់ឡើយ។

គ១០ អង្គភាពមួយដែលផ្លាស់ប្តូរពីវិធីសាស្ត្រមូលធនផ្ទាល់ទៅការកត់ត្រាទ្រព្យសកម្ម និងបំណុល ត្រូវផ្តល់នូវការសម្រប សម្រួលមួយរវាងការវិនិយោគដែលមិនទទួលស្គាល់ជាមួយនឹងទ្រព្យសកម្មនិងបំណុលដែលបានទទួលស្គាល់ រួមជាមួយនឹងភាពខុសគ្នា ដែលនៅសល់ ដែលបានកែសម្រួលជាមួយនឹងប្រាក់ចំណេញរក្សាទុក នៅដើមគ្រានៃការិយបរិច្ឆេទដំបូងបំផុតដែលបានបង្ហាញ។

គ១១ ការលើកលែងនូវការទទួលស្គាល់លើកដំបូងនៅក្នុងកថាខណ្ឌ ១៥ និងកថាខណ្ឌ ២៤ នៃស្តង់ដាគណនេយ្យអន្តរជាតិ ១២ មិនអនុវត្តឡើយនៅពេលអង្គភាពទទួលស្គាល់ទ្រព្យសកម្មនិងបំណុលទាក់ទងនឹងភាគកម្មរបស់ខ្លួននៅក្នុងប្រតិបត្តិការរួមគ្នា។

**មាត្រាអន្តរកាលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ដាច់ដោយឡែករបស់អង្គភាព**

គ១២ អង្គភាពមួយ ដោយអនុលោមតាមកថាខណ្ឌ ១០ នៃស្តង់ដាគណនេយ្យអន្តរជាតិ ២៧ ដែលពីមុន កត់ត្រានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់ខ្លួននូវភាគកម្មនៅក្នុងប្រតិបត្តិការរួមគ្នាថាជាការវិនិយោគតាមតម្លៃដើម ឬដោយអនុលោមតាម ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩ ត្រូវៈ

(ក) មិនទទួលស្គាល់ការវិនិយោគ និងទទួលស្គាល់ទ្រព្យសកម្ម និងបំណុល សម្រាប់ភាគកម្មនៅក្នុងប្រតិបត្តិការរួមគ្នា តាមបរិមាណដែលបានកំណត់ដោយអនុលោមតាមកថាខណ្ឌ គ៧-គ៩។

(ខ) ផ្តល់នូវការសម្រសម្រួលមួយ រវាងការវិនិយោគ ដែលមិនទទួលស្គាល់ជាមួយនឹងទ្រព្យសកម្មនិងបំណុលបានទទួលស្គាល់ រួមជា

មួយនឹងភាពខុសគ្នាដែលនៅសល់ដែលបានកែមសម្រួល នៅក្នុងប្រាក់ចំណេញរក្សាទុក នៅដើមគ្រានៃការិយបរិច្ឆេទ ដំបូងបំផុតដែលបានបង្ហាញ។

**គ១៣** ការលើកលែងនូវការទទួលស្គាល់លើកដំបូងនៅក្នុងកថាខណ្ឌ ១៥ និង កថាខណ្ឌ ២៤ នៃស្តង់ដាគណនេយ្យអន្តរជាតិ ១២ មិនអនុវត្តឡើយ នៅពេលអង្គភាពទទួលស្គាល់ទ្រព្យសកម្មនិងបំណុលទាក់ទងនឹងភាគកម្ម របស់ខ្លួន នៅក្នុងប្រតិបត្តិការរួមគ្នា នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក ដែលកើតចេញពីការអនុវត្តន៍ការតម្រូវអន្តរ កាលសម្រាប់ប្រតិបត្តិការរួមគ្នា ដែលបានសំដៅដល់កថាខណ្ឌ គ១២។

### សេចក្តីយោងចំពោះស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩

គ១៤ ប្រសិនបើ អង្គភាពអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ សេចក្តីយោងនានាចំពោះស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ ត្រូវមើលថាជាសេចក្តីយោង ចំពោះស្តង់ដារ គណនេយ្យអន្តរជាតិ ៣៩ *ឧបករណ៍ ហិរញ្ញវត្ថុៈ ការទទួលស្គាល់និងការវាស់វែង*។

## ការដកចេញស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិផ្សេងៗ

គ១៥ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះជំនួសស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិខាងក្រោមៈ

(ក) ស្តង់ដារគណនេយ្យអន្តរជាតិ ៣១ *ភាគកម្ម នៅក្នុងក្រុមហ៊ុនវិនិយោគរួមទុន* និង

(ខ) SIC-១៣ *អង្គភាពមានអភិបាលភាពរួមគ្នា--ការរួមចំណែកមិនមែនរូបិយវត្ថុដោយអ្នកដាក់ទុនរួមគ្នា*

## ឧបសម្ព័ន្ធ ឃ

**ឧបសម្ព័ន្ធនេះកំណត់អំពីកំណែប្រែចំពោះស្តង់ដារបាយការណ៍ហិរញ្ញវត្ថុផ្សេងៗដែលជាផលវិបាកនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលដែលបានចេញផ្សាយស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១។ អង្គភាពត្រូវអនុវត្តកំណែប្រែ សម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ឬក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។ ប្រសិនបើ អង្គភាពអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១ សម្រាប់ការិយបរិច្ឆេទមុន អង្គភាពត្រូវអនុវត្តកំណែប្រែ សម្រាប់ការិយបរិច្ឆេទមុននោះ។ កថាខណ្ឌដែលបានកែប្រែត្រូវបានបង្ហាញជាមួយអត្ថបទថ្មី ដែលមានការគូសបន្ទាត់ពីក្រោម ហើយអត្ថបទដែលលុបចោលត្រូវបានគូសបន្ទាត់ផ្តាច់។**

ឃ១ តារាងនេះបង្ហាញរបៀបសេចក្តីសំអាងខាងក្រោម ត្រូវបានកែប្រែនៅក្នុងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិផ្សេងៗ

<table>
<tr><th>សំអាងបច្ចុប្បន្នចំពោះ</th><th>មាននៅក្នុង</th><th>នៅក្នុង</th><th>ត្រូវបានកែប្រែទៅជាសេចក្តីសំអាងចំពោះ</th></tr>
<tr><td rowspan="2">ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៣១ ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន</td><td>ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ២</td><td>កថាខណ្ឌ ៥</td><td rowspan="2">ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ កិច្ច ព្រមព្រៀងរួមគ្នា</td></tr>
<tr><td>ស្តង់ដារបាយការណ៍ហិរញ្ញ</td><td>កថាខណ្ឌ ៥<br>ខ៤.៣.១២(គ)</td></tr>
</table>

| | | | |
|---|---|---|---|
| | វត្ថុអន្តរជាតិ៩ (បានចេញផ្សាយនៅខែតុលា ឆ្នាំ២០១០) | | |
| | ស្តង់ដារគណ-នេយ្យអន្តរជាតិ ៣៦ | កថាខណ្ឌ៤(គ) | |
| | IFRIC 5 | សេចក្តីសំអាង | |
| | IFRIC 9 | កថាខណ្ឌ៥(គ) | |
| ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ២៨ *ការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ* | ស្តង់ដារគណ-នេយ្យអន្តរជាតិ ១៨ | កថាខណ្ឌ ៦(ខ) | ស្តង់ដារគណនេយ្យអន្តរជាតិ ២៨ *ការវិនិយោគនៅក្នុង ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងក្រុមហ៊ុនរួមទុន* |
| | ស្តង់ដារគណ-នេយ្យអន្តរជាតិ ៣៦ | កថាខណ្ឌ ៤(ខ) | |
| | IFRIC 5 | សេចក្តីសំអាង | |
| ប្រតិបត្តិការរួមគ្នាលើ | ស្តង់ដារគណ-នេយ្យអន្តរជាតិ | កថាខណ្ឌ ជ(ក)(ឈ) | ប្រតិប្តិការរួមគ្នានៃ |

| | | | |
|---|---|---|---|
| | ២៤ | និង១១(ខ) | |
| អង្គភាពមានអភិបាលភាពរួមគ្នា | ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១ | ចំណងជើងខាងមុខ កថាខណ្ឌ ៣១, កថាខណ្ឌ ៣១និងឃ១(ឆ), ចំណងជើងខាងមុខកថាខណ្ឌ ឃ១៤,កថាខណ្ឌ ឃ១៤និង ឃ១៥ | ការវិនិយោគរួមទុន |
| | ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៣៦ | ចំណងជើងខាងមុខ កថាខណ្ឌ ១២ជ, កថាខណ្ឌ ១២ជនិង ១២ជ(2) | |
| ការវិនិយោគរួមទុន | ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១២ | កថាខណ្ឌ២, កថាខណ្ឌ១៥, កថាខណ្ឌ១៨(ង) កថាខណ្ឌ២៤, ចំណងជើងខាងមុខកថាខណ្ឌ | កិច្ចព្រមព្រៀងរួមទុន |

| | | | |
|---|---|---|---|
| | | ៣៨, កថាខណ្ឌ៣៨, កថាខណ្ឌ៣៨(ក), កថាខណ្ឌ៤៤, កថាខណ្ឌ៤៥, កថាខណ្ឌ៨១(ច), កថាខណ្ឌ៨៧, កថាខណ្ឌ៨៧គ | |
| | ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ២១ | និយមន័យ “ប្រតិបត្តិការបរទេស” នៅក្នុងកថាខណ្ឌ ៨ និងកថាខណ្ឌ១១ និងកថាខណ្ឌ១៨ | |
| អ្នកវិនិយោគរួមទុន | ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ២៤ | កថាខណ្ឌ១១(ខ) និង កថាខណ្ឌ១៩(ង) | អ្នកវិនិយោគរួមទុន |

ឃ២ កថាខណ្ឌ ៣៩ថ ត្រូវបានបន្ថែមដូចខាងក្រោមៈ

៣៩ថ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ *របាយការណ៍ហិរញ្ញវត្ថុ សមាស* និងស្តង់ដា របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួម* ដែលបានចេញផ្សាយ នៅខែឧសភា ឆ្នាំ២០១១ ត្រូវបានកែប្រែ កថាខណ្ឌ ៣១, កថាខណ្ឌ ខ៧, កថាខណ្ឌ គ១, កថាខណ្ឌ ឃ១, កថាខណ្ឌ ឃ១៤, និង កថាខណ្ឌ ឃ១៥, និងបានបន្ថែម កថាខណ្ឌ ឃ១៣។ អង្គភាពត្រូវអនុវត្តកំណែប្រែទាំងនោះនៅពេលខ្លួនអនុវត្តស្តង់ដា របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ អន្តរជាតិ១១ ។

ឃ៣ កថាខណ្ឌ ឃ១ ត្រូវបានកែប្រែដូចខាងក្រោមៈ

ឃ១ អង្គភាពអាចជ្រើសរើសប្រើការលើកលែងមួយ ឬច្រើនដូចខាងក្រោមៈ

(ក) ......

(p)ញែកចេញពីគ្នាទ្រព្យសកម្មនិងបំណុលដែលនៅជាមួយនឹងឧបករណ៍ហិរញ្ញវត្ថុជាមូលធនផ្ទាល់

(កថាខណ្ឌ ឃ២៥) និង

(q) អតិផរណាលោតផ្លោះខ្ពស់ខ្លាំង (កថាខណ្ឌ ឃ២៦-ឃ៣០) និង

(r) កិច្ចព្រមព្រៀងរួម(កថាខណ្ឌ ឃ៣១)។

ឃ៤ បន្ទាប់ពី កថាខណ្ឌ ឃ៣០, ចំណងជើង និងកថាខណ្ឌ ឃ៣១ ត្រូវបានបន្ថែម។

**កិច្ចព្រមព្រៀងរួម**

ឃ៣១ អ្នកប្រើប្រាស់លើកដំបូង អាចអនុវត្តមាត្រាអន្តរកាល នៅក្នុងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ ជាមួយនឹងការលើកលែងខាងក្រោម។ នៅពេលមានការផ្លាស់ប្តូរពីការធ្វើសមាសជាចំណែកៗ ទៅជាវិធីសាស្រ្តមូលធនផ្ទាល់, អ្នកប្រើប្រាស់លើកដំបូង ត្រូវធ្វើតេស្តលើការថយចុះតម្លៃនៃការវិនិយោគ ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិ៣៦ នៅដើមគ្រានៃការិយបរិច្ឆេទដំបូងបំផុតដែលបានបង្ហាញ, ដោយមិនគិតថា តើមានសូចនករដែលថា ការវនិយោគ នោះត្រូវបានថយចុះតម្លៃនោះឡើយ ។ ការថយចុះតម្លៃណាមួយក៏ដោយត្រូវតែបានទទួលស្គាល់ថាជាការកែសម្រួលទៅនឹងប្រាក់ចំណេញរក្សាទុកនៅដើមគ្រានៃការិយបរិច្ឆេទដំបូងបំផុត ដែលបានបង្ហាញ។

## ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ២ *ការទូទាត់ផ្អែកលើប័ណ្ណភាគហ៊ុន*

ឃ៥ កថាខណ្ឌ ៦៣ក ត្រូវបានបន្ថែមដូចខាងក្រោមៈ

៦៣ក ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ *របាយការណហិរញ្ញវត្ថុសមាស និង*ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១, ដែលបានចេញផ្សាយ នៅខែឧសភា ឆ្នាំ២០១១, បានកែប្រែកថាខណ្ឌ ៥ និងឧបសម្ពន្ធ ក។ អង្គភាព ត្រូវអនុវត្តកំណែប្រែទាំងនោះនៅពេលអនុវត្តស្តង់ដា របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១។

ឃ៦ កថាខណ្ឌ២៨ត្រូវបានកែប្រែដូចខាងក្រោមៈ

២៨ អង្គភាពត្រូវដាក់ចូលនូវការកែសម្រួល ដែលបានតម្រូវទៅលើតម្លៃលើបញ្ជីនៃទ្រព្យសកម្មរយៈពេលវែង ដែលបញ្ឈប់ពីការចាត់ថ្នាក់ សម្រាប់ការលក់ពីក្នុងរបាយការណ៍ចំណេញ ឬខាត (ន័យលក្ខណៈត្រូវបានលុបចោល)របស់ប្រតិបត្តិការកំពុងបន្តនៅក្នុងការិយបរិច្ឆេទដែលលក្ខណវិនិច្ឆ័យនៅក្នុងកថាខណ្ឌ ៧-៩ លែងឆ្លើយតប។របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគិតចាប់តាំងពីការធ្វើចំណាត់ថ្នាក់ទុកសម្រាប់លក់ ត្រូវបានកែប្រែទៅតាមប្រសិនបើការលក់ចោលជាក្រុមឬទ្រព្យសកម្មរយៈពេលវែងដែលលែងត្រូវ បានចាត់ថ្នាក់ថាជាទុក សម្រាប់លក់គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធ, ប្រតិបត្តិការរួមគ្នា, ការវិនិយោគរួមគ្នា ក្រុមហ៊ុនញាតិសម្ព័ន្ធ, ឬផ្នែកមួយនៃភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន ឬក្រុមហ៊ុនញាតិសម្ព័ន្ធ។ អង្គភាពត្រូវបង្ហាញថា ការកែសម្រួលនៅក្នុងចំណងជើងដូចគ្នានៅក្នុងរបាយការណ៍លទ្ធផលសរុបរួមដែលបានប្រើ ដើម្បីបង្ហាញចំណេញឬការខាតបង់ ប្រសិនបើមានត្រូវបានទទួលស្គាល់ដោយអនុលោមតាម កថាខណ្ឌ ៣៧។

ឃ៧ កថាខណ្ឌ៤៤ឆ ត្រូវបានបន្ថែម ដូចខាងក្រោមៈ

៤៤ឆ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួម,* ដែលបានចេញផ្សាយ នៅខែឧសភា ឆ្នាំ២០១១, បានកែប្រែ

កថាខណ្ឌ ២៨។ អង្គភាព ត្រូវអនុវត្តកំណែប្រែនោះនៅពេលអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១។

## ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៧: *ឧបករណ៍ហិរញ្ញវត្ថុ: ការលាតត្រដាងព័ត៌មាន*

---

ឃ៨ កថាខណ្ឌ៣(ក) ត្រូវបានកែប្រែដូចខាងក្រោម:

៣ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះត្រូវតែអនុវត្តដោយគ្រប់អង្គភាពទាំងអស់ ចំពោះគ្រប់ប្រភេទ ឧបករណ៍ហិរញ្ញវត្ថុ លើកលែងតែ:

(ក) បណ្តាភាគកម្មនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ, ក្រុមហ៊ុនញាតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុនដែលត្រូវបានកំណត់ដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ *របាយការណ៍ហិរញ្ញវត្ថុសមាស*, ស្តង់ដាគណនេយ្យអន្តរជាតិ២៧ ~~*របាយការណ៍ហិរញ្ញវត្ថុសមាសនិងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក*~~, ឬស្តង់ដាគណនេយ្យអន្តរជាតិ២៨ ~~*ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ*~~ *និងក្រុមហ៊ុនរួមទុន*, ~~ឬស្តង់ដាគណនេយ្យអន្តរជាតិ៣១ *ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន*~~។ ទោះជាយ៉ាងណា នៅក្នុងករណីខ្លះ ស្តង់ដាគណនេយ្យអន្តរជាតិ២៧, ឬស្តង់ដាគណនេយ្យអន្តរជាតិ២៨, ~~ឬស្តង់ដាគណនេយ្យអន្តរជាតិ៣១~~ អនុញ្ញាតិឲ្យអង្គភាពកំណត់ភាគកម្មនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ,

ក្រុមហ៊ុនញាតិសម្ពន្ធ័ ឬ ក្រុមរួមទុន ដោយប្រើ ស្តង់ដាគណនេយ្យអន្តរជាតិ៣៩, នៅក្នុងករណីទាំងនោះ......

ឃ៩ កថាខណ្ឌ ៤៤០ ត្រូវបានកែប្រែដូចខាងក្រោម:

៤៤០ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និងស្តង់ដារបាយ-ការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១ *កិច្ចព្រមព្រៀងរួម,* បានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១, បានកែប្រែកថាខណ្ឌ៣។ អង្គភាពត្រូវអនុវត្តកំណែប្រែនោះ នៅពេលអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០និងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

## ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩: *ឧបករណ៍ហិរញ្ញវត្ថុ* (បានកែប្រែនៅខែវិច្ឆិកា ឆ្នាំ២០០៩)

ឃ១០ កថាខណ្ឌ៨.២.១ ត្រូវបានបន្ថែម ដូចខាងក្រោម:

៨.២.១ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និងស្តង់ដារបាយ-ការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួម,* បានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១, បានកែប្រែកថាខណ្ឌ គ៨ និងបានលុបចោល កថាខណ្ឌ គ១៨-គ២៣ និងចំណងជើងពាក់ពន្ធ័។ អង្គភាពត្រូវអនុវត្តកំណែប្រែនោះនៅពេលអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១។

ឃ១១ ឧបសម្ពន្ធ័ គ នៅក្នុងកថាខណ្ឌ គ៨ កំណែប្រែចំពោះកថាខណ្ឌ៣(ក) នៃស្តង់ដា របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៧ *ឧបករណ៍ហិរញ្ញវត្ថុ: ការលាតត្រដាងព័ត៌មាន* ត្រូវបានកែប្រែដូចខាងក្រោម:

៣ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះត្រូវអនុវត្ត ដោយគ្រប់អង្គភាពទាំងអស់ ចំពោះគ្រប់ប្រភេទ ឧបករណ៍ហិរញ្ញវត្ថុ លើកលែងតែ:

(ក) បណ្តាភាគកម្មនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ, ក្រុមហ៊ុនញាតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុនដែលត្រូវបានកំណត់ដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០*របាយការណ៍ហិរញ្ញវត្ថុសមាស*, ស្តង់ដាគណនេយ្យអន្តរជាតិ២៧ ~~*របាយការណ៍ហិរញ្ញវត្ថុសមាសនិងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក*~~, ឬ ស្តង់ដាគណនេយ្យអន្តរជាតិ២៨ ~~*ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ*~~*និងក្រុមហ៊ុនរួមទុន*, ~~ឬស្តង់ដាគណនេយ្យអន្តរជាតិ៣១ *ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន*។~~ ទោះជាយ៉ាងណា នៅក្នុងករណីខ្លះ ស្តង់ដាគណនេយ្យអន្តរជាតិ២៧, ឬ ស្តង់ដាគណនេយ្យអន្តរជាតិ២៨, ~~ឬស្តង់ដាគណនេយ្យអន្តរជាតិ៣១~~ អនុញ្ញាតិឲ្យអង្គភាពកំណត់ភាគកម្មនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ, ក្រុមហ៊ុនញាតិសម្ព័ន្ធ ឬ ក្រុមរួមទុន ដោយប្រើស្តង់ដារគណនេយ្យអន្តរជាតិ៣៩, នៅក្នុងករណីទាំងនោះ.......

យ១២ ចំណងជើងខាងលើកថាខណ្ឌ គ២០ និង កថាខណ្ឌ គ២០ និង គ២១ ត្រូវបានលុបចោល។

ឃ១៣ ចំណងជើងខាងលើកថាខណ្ឌ គ២២ និង កថាខណ្ឌ គ២២ និង គ២៣ ត្រូវបានលុបចោល។

**ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ *ឧបករណ៍ហិរញ្ញវត្ថុ* (បានចេញផ្សាយនៅខែតុលា ឆ្នាំ២០១០)**

---

ឃ១៤ កថាខណ្ឌ ៧.១.២ត្រូវបានបន្ថែម ដូចខាងក្រោម៖

៧.១.២ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួម,* បានចេញផ្សាយនៅ ខែឧសភា ឆ្នាំ២០១១, បានកែប្រែ កថាខណ្ឌ ៣.២.១, កថាខណ្ឌ ខ៣.២.១-កថាខណ្ឌ ខ៣.២.៣, កថាខណ្ឌ ខ៤.៣.១២(គ), កថាខណ្ឌ ខ៥.៧.១៥, កថាខណ្ឌ គ១១ និង កថាខណ្ឌ គ៣០ និងបានលុបចោល កថាខណ្ឌ គ២៣-គ២៨ និងចំណងជើងពាក់ពន្ធ័។ អង្គភាពត្រូវអនុវត្តកំណែប្រែនោះនៅពេលអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០និងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១។

ឃ១៥ ឧបសម្ពន្ធ័ **គ**នៅក្នុងកថាខណ្ឌ គ១១ កំណែប្រែចំពោះកថាខណ្ឌ ៣(ក) នៃស្តង់ដា របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៧ *ឧបករណ៍ហិរញ្ញវត្ថុ: ការលាតត្រដាងព័ត៌មាន* ត្រូវបានកែប្រែដូចខាងក្រោម៖

៣ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះត្រូវអនុវត្តដោយគ្រប់អង្គភាពទាំងអស់ ចំពោះគ្រប់ប្រភេទ ឧបករណ៍ហិរញ្ញវត្ថុ លើកលែងតែ:

(ក) បណ្តាភាគកម្មនៅក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ័, ក្រុមហ៊ុនញាតិសម្ពន្ធ័ ឬ ក្រុមហ៊ុនរួមទុនដែលត្រូវបានកំណត់

ដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០*របាយការណ៍ហិរញ្ញវត្ថុសមាស*, ស្តង់ដាគណនេយ្យអន្តរជាតិ២៧ ~~*របាយការណ៍ហិរញ្ញវត្ថុសមាសនិងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក*~~, ឬ ស្តង់ដាគណនេយ្យអន្តរជាតិ២៨ ~~*ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ*~~*និងក្រុមហ៊ុនរួមទុន*, ~~ឬស្តង់ដាគណនេយ្យអន្តរជាតិ៣១ *ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន*~~។ ទោះជាយ៉ាងណា នៅក្នុងករណីខ្លះ ស្តង់ដាគណនេយ្យអន្តរជាតិ២៧, ឬ ស្តង់ដាគណនេយ្យអន្តរជាតិ២៨, ~~ឬស្តង់ដាគណនេយ្យអន្តរជាតិ៣១~~ អនុញ្ញាតិឲ្យអង្គភាពកំណត់ភាគកម្មនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ, ក្រុមហ៊ុនញាតិសម្ព័ន្ធ ឬ ក្រុមរួមទុន ដោយប្រើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩, នៅក្នុងករណីទាំងនោះ.......

ឃ១៦ ចំណងជើងខាងលើកថាខណ្ឌ គ២៥ និង កថាខណ្ឌ ក២៥ និង គ២៦ ត្រូវបានលុបចោល។

ឃ១៧ ចំណងជើងខាងលើកថាខណ្ឌ គ២៧ និង កថាខណ្ឌ គ២៧ និង គ២៨ ត្រូវបានលុបចោល។

ឃ១៨ កថាខណ្ឌ គ៣០ កំណែប្រែចំពោះកថាខណ្ឌ ៤(ក) នៃស្តង់ដារគណនេយ្យអន្តរជាតិ ៣២ *ឧបករណ៍ហិរញ្ញវត្ថុៈ ការដាក់បង្ហាញ* ត្រូវបានកែប្រែដូចខាងក្រោមៈ

៤ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះត្រូវអនុវត្តដោយគ្រប់អង្គភាពទាំងអស់ ចំពោះគ្រប់ប្រភេទ ឧបករណ៍ហិរញ្ញវត្ថុលើកលែងតែ:

(ក) បណ្តាភាគកម្មនៅក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ័, ក្រុមហ៊ុនញាតិសម្ពន្ធ័ ឬ ក្រុមហ៊ុនរួមទុនដែលត្រូវបានកំណត់ដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ *របាយការណ៍ហិរញ្ញវត្ថុសមាស*, ស្តង់ដាគណនេយ្យអន្តរជាតិ២៧ ~~*របាយការណ៍ហិរញ្ញវត្ថុសមាសនិងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក*~~, ឬ ស្តង់ដាគណនេយ្យអន្តរជាតិ២៨ ~~*ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ពន្ធ័និងក្រុមហ៊ុនរួមទុន*~~, ~~ឬស្តង់ដាគណនេយ្យអន្តរជាតិ៣១ *ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន។*~~ ទោះជាយ៉ាងណា នៅក្នុងករណីខ្លះ ស្តង់ដាគណនេយ្យអន្តរជាតិ២៧, ឬ ស្តង់ដាគណនេយ្យអន្តរជាតិ២៨, ~~ឬស្តង់ដាគណនេយ្យអន្តរជាតិ៣១~~ អនុញ្ញាតិឲ្យអង្គភាពកំណត់ភាគកម្មនៅក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ័, ក្រុមហ៊ុនញាតិសម្ពន្ធ័ ឬ ក្រុមរួមទុន ដោយប្រើស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩, នៅក្នុងករណីទាំងនោះ......

**ស្តង់ដារគណនេយ្យអន្តរជាតិ ៧** *របាយការណ៍លំហូរសាច់ប្រាក់*

---

ឃ១៩ [មិនអាចអនុវត្តបានចំពោះការតម្រូវ]

ឃ២០ កថាខណ្ឌ ៣៧ និង កថាខណ្ឌ៣៨ ត្រូវបានកែប្រែដូចខាងក្រោមៈ

៣៧ នៅពេលកំណត់រកការវិនិយោគនៅក្នុងក្រុមហ៊ុនញ្ញតិសម្ព័ន្ធ, ក្រុមហ៊ុនរួមទុន ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ដោយបានប្រើប្រាស់វិធីសាស្ត្រមូលធនផ្ទាល់ ឬវិធីសាស្ត្រថ្លៃដើម, វិនិយោគិនកម្រិតការរាយការណ៍របស់ខ្លួន នៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់ទៅក្នុងលំហូរសាច់ប្រាក់រវាងខ្លួនឯងនិងក្រុមហ៊ុនរងការវិនិយោគ, ជាឧទាហរណ៍, ភាគលាភ និង ប្រាក់បុរេប្រទាន។

៣៨

~~អង្គភាពដែលរាយការណ៍ភាគកម្មរបស់ខ្លួននៅក្នុងអង្គភាពដែលមានអភិបាលភាពរួម(មើល ស្តង់ដាគណនេយ្យអន្តរជាតិ៣១ *ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន*) ដោយវិធីសាស្ត្រនៃការធ្វើសមាសជាផ្នែកៗដោយរួមមាន នៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់សមាស ចំណែកនៃលំហូរសាច់ប្រាក់របស់អង្គភាពដែលមានអភិបាលភាពរួម។~~

អង្គភាពដែលរាយការណ៍ភាគកម្ម~~មែមនោះ~~នៅក្នុងក្រុមហ៊ុនញ្ញតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុន ដោយប្រើវិធីសាស្ត្រមូលធនផ្ទាល់ ដែលរួមមាននៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់ នូវសាច់ប្រាក់ដែលពាក់ពន្ធ័នឹងការវិនិយោគរបស់ខ្លួននៅក្នុង~~អង្គភាពដែលមានអភិបាលភាពរួម~~ ក្រុមហ៊ុនញ្ញតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុន, និង ការបែងចែកនិងការទូទាត់សងនិងចំណូលផ្សេងទៀតរវាង

ខ្លួនឯងនិង~~អង្គភាពដែលមានអភិបាលភាពរួម~~

ក្រុមហ៊ុនញាតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុន។

ឃ២១ កថាខណ្ឌ ៥០(ខ) ត្រូវបានលុបចោល។

ឃ២២ កថាខណ្ឌ៥៧ ត្រូវបានបន្ថែម ដូចខាងក្រោមៈ

៥៧ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និងស្តង់ដារបាយ-ការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួម,* បានចេញផ្សាយ នៅ ខែឧសភា ឆ្នាំ២០១១, បានកែប្រែ កថាខណ្ឌ៣៧, កថាខណ្ឌ៣៨ និង កថាខណ្ឌ៤២ខ និងលុបចោល កថាខណ្ឌ ៥០(ខ)។ អង្គភាព ត្រូវអនុវត្តកំណែប្រែនោះនៅពេលអនុវត្ត ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១។

## ស្តង់ដាគណនេយ្យអន្តរជាតិ ១២ *ពន្ធលើប្រាក់ចំណេញ*

ឃ២៣ [មិនអាចអនុវត្តបានចំពោះការតម្រូវ]

ឃ២៤ [មិនអាចអនុវត្តបានចំពោះការតម្រូវ]

ឃ២៥ កថាខណ្ឌ៣៩ ត្រូវបានកែប្រែដូចខាងក្រោមៈ

**៣៩ អង្គភាពត្រូវទទួលស្គាល់បំណុលពន្ធ សម្រាប់គ្រប់ភាពខុសគ្នាជាបណ្តោះ សន្នដែលអាចជាប់ពន្ធដែល ពាក់ពន្ធ័ជាមួយការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ, សាខា និងក្រុមហ៊ុនញាតិសម្ព័ន្ធ និងភាគកម្មនៅ ក្នុងកិច្ចព្រមព្រៀងរួម លើកលែងតែលក្ខខណ្ឌទាំងពីរត្រូវបានបំពេញៈ**

(ក) ក្រុមហ៊ុនមេ, វិនិយោគិន, អ្នកវិនិយោគរួមទុន ឬ ប្រតិបត្តិការរួមទុន អាចត្រួតពិនិត្យពេលវេលានៃភាពបញ្ច្រាសគ្នា នៃភាពខុសគ្នាជាបណ្តោះអាសន្ន, និង

(ខ)......

ឃ២៦ កថាខណ្ឌ ៤៣ ត្រូវបានកែប្រែដូចខាងក្រោមៈ

៤៣ កិច្ចព្រមព្រៀងរវាងភាគីនានានៅក្នុងកិច្ចព្រមព្រៀងរួម ជាធម្មតាទាក់ទងនឹងការបែងចែកប្រាក់ចំណេញ និងកំណត់ថាតើការសម្រេច ចិត្តលើបញ្ហាទាំងនេះតម្រូវឲ្យមានការយល់ព្រមពីភាគីទាំងអស់ ឬពីក្រុមវិនិយោគិនភាគច្រើននៃបណ្តាភាគីរួមទុន។នៅពេលដែលវិនិយោគិនរួមទុន ឬ ប្រតិបត្តិកររួម អាចធ្វើអភិបាលលើពេលមានវេលាកំណត់នៃការបែងចែកនៃចំណែកប្រាក់ចំណេញរបស់កិច្ចព្រមព្រៀងរួម និង វាប្រហែលជាអាចថាចំណែកនៃប្រាក់ចំណេញរបស់ខ្លួននឹងមិនអាចត្រូវបានបែងចែកនាពេលអនាគតដ៏ខ្លីខាងខាងមុខបាន, បំណុលពន្ធពន្យាមិនត្រូវបានទទួលស្គាល់ឡើយ។

ឃ២៧ កថាខណ្ឌ ៩៨ក ត្រូវបានបន្ថែមដូចខាងក្រោមៈ

៩៩ក ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួម*, បានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១, បានកែប្រែកថាខណ្ឌ ២, កថាខណ្ឌ ១៥ និងកថាខណ្ឌ ១៨(ង), កថាខណ្ឌ ២៤, កថាខណ្ឌ៣៨, កថាខណ្ឌ៣៩, កថាខណ្ឌ៤៣-កថាខណ្ឌ៤៥, កថាខណ្ឌ៨១(ច), កថាខណ្ឌ៨៧និងកថាខណ្ឌ ៨៧គ។អង្គភាព

ត្រូវអនុវត្តកំណែប្រែនោះនៅពេលអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

## ស្តង់ដាគណនេយ្យអន្តរជាតិ ១៨ ចំណូល

យ២៨ [មិនអាចអនុវត្តបានចំពោះការតម្រូវ]

ខ២៩ កថាខណ្ឌ ៤១ត្រូវបានបន្ថែមដូចខាងក្រោមៈ

៤១ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួម,* បានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១, បានកែប្រែកថាខណ្ឌ ៦(ខ)។អង្គភាពត្រូវអនុវត្តកំណែប្រែនោះនៅពេលអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

## ស្តង់ដារគណនេយ្យអន្តរជាតិ២១ ផលប៉ះពាល់នៃការផ្លាស់ប្តូរនៃអត្រាប្តូរប្រាក់បរទេស

យ៣០ [មិនអាចអនុវត្តបានចំពោះការតម្រូវ]

យ៣១ នៅក្នុងកថាខណ្ឌ៣(ក) និងកថាខណ្ឌ៤៤ “ការធ្វើសមាសជាផ្នែក” និងក្នុងកថាខណ្ឌ ៣៣ “ត្រូវធ្វើសមាសជាផ្នែក” ត្រូវបានលុបចោល។

យ៣២ នៅក្នុងកថាខណ្ឌ៤៥, “ស្តង់ដាគណនេយ្យអន្តរជាតិ៣១ *ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន*” ត្រូវបានលុបចោល។

យ៣៣ ក្នុងកថាខណ្ឌ ៤៦ ប្រយោគចុងក្រោយ ត្រូវបានកែប្រែដូចខាងក្រោមៈ

៤៦ .....

វិធីសាស្ត្រដូចគ្នាត្រូវបានប្រើនៅក្នុងការអនុវត្តន៍វិធីសាស្ត្រមូលធនផ្ទាល់ចំពោះក្រុមហ៊ុនញាតិសម្ពន្ធ័, ~~និងក្រុមហ៊ុនរួមទុននិងការអនុវត្តន៍នូវការធ្វើសមាសជាផ្នែកចំពោះក្រុមហ៊ុនរួមទុន~~ ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិ២៨

ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ពន្ធ័
និងស្តង់ដាគណនេយ្យអន្តរ ជាតិ៣១
(ដែលបានកែប្រែនៅឆ្នាំ២០១១)។

យ៣៤ កថាខណ្ឌ៤៨ក ត្រូវបានកែប្រែដូចខាងក្រោម៖

៤៨ក

ជាការបន្ថែមទៅលើការលក់ចេញនូវភាគកម្មទាំងស្រុងរបស់អង្គភាពនៅក្នុងប្រតិបត្តិការបរទេស, ការលក់ចេញជាផ្នែកៗខាងក្រោមត្រូវបានកំណត់ថាជាការលក់ចេញ មើទោះបីជា អង្គភាពរក្សាទុកភាគកម្មនៅក្នុងអតីតក្រុមហ៊ុនបុត្រសម្ពន្ធ័, ក្រុមហ៊ុនញាតិសម្ពន្ធ័ ឬអង្គភាពមានអភិបាលភាពរួមគ្នា៖

(ក) នៅពេលដែលការលក់ចេញជាផ្នែកៗទាក់ទងនឹងការបាត់បង់អភិបាលភាពនៅក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ័ ដែលមាននៅក្នុងប្រតិបត្តិការបរទេស ដោយមិនគិតថាតើអង្គភាពរក្សាទុកភាគកម្មមិនមានអភិបាលភាពនៅក្នុងអតីតក្រុមហ៊ុនបុត្រសម្ពន្ធ័បន្ទាប់ពីការលក់ចេញជាផ្នែក, និង

(ខ) នៅពេលដែលភាគកម្មបានរក្សាទុកបន្ទាប់ពីការលក់ចេញជាផ្នែកនៃភាគកម្មនៅក្នុង ការបាត់បង់ឥទ្ធិពលដ៏សំខាន់នៅក្នុងកិច្ចព្រមព្រៀងរួមឬការលក់ចេញមួយផ្នែកនៃភាគកម្មនៅក្នុងក្រុមហ៊ុនញាតិសម្ពន្ធ័ ដែលមាននៅក្នុងប្រតិបត្តិការបរទេស

គឺជាទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងប្រតិបត្តិការបរទេស, និង

(គ) ~~ការបាត់បង់អភិបាលភាពរួមគ្នាក្នុងអង្គភាពដែលមានអភិបាលភាពរួមគ្នាដែលមាននៅក្នុងប្រតិបត្តិការបរទេស។~~

ឃ៣៥ កថាខណ្ឌ៦០ច ត្រូវបានបន្ថែមដូចខាងក្រោមៈ

៦០ច ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និងស្តង់ដារបាយ-ការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួម,* បានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១, បានកែប្រែកថាខណ្ឌ ៣(ក), កថាខណ្ឌ៨, កថាខណ្ឌ១១, កថាខណ្ឌ១៨, កថាខណ្ឌ១៩, កថាខណ្ឌ៣៣, កថាខណ្ឌ៤៤-កថាខណ្ឌ៤៦, និងកថាខណ្ឌ ៤៨ក។ អង្គភាពត្រូវអនុវត្តកំណែប្រែនោះនៅពេលអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ និង ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

## ស្តង់ដារ គណនេយ្យអន្តរជាតិ២៤ ការលាតត្រដាងព័ត៌មានរបស់ភាគីពាក់ព័ន្ធ

ឃ៣៦ កថាខណ្ឌ៣ត្រូវបានកែប្រែដូចខាងក្រោមៈ

៣ **ស្តង់ដា នេះតម្រូវឲ្យមានការលាតត្រដាងព័ត៌មាន អំពីទំនាក់ទំនងរបស់ភាគីពាក់ព័ន្ធ, ប្រតិបត្តិការនិង សមតុល្យនៅជំពាក់ដែលរួមមានទាំង កាតព្វកិច្ចបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសមាស និងរបាយកាណ៍ដាច់ដោយឡែករបស់ក្រុមហ៊ុនមេ, ~~អ្នកវិនិយោគរួមទុន~~ ឬវិនិយោគិនដែលមានអភិបាលភាពរួមនៅក្នុង ឬ មានឥទ្ធិពលសំខាន់ទៅលើក្រុមហ៊ុនរងការវិនិយោគដែលបានបង្ហា**

ញ្ញដោយអនុលោមតាម ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ *របាយការណ៍ហិរញ្ញវត្ថុសមាស* ឬ ស្តង់ដាគណនេយ្យអន្តរជាតិ២៧ ~~របាយការហិរញ្ញវត្ថុសមាសនិង~~របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក។ស្តង់ដានេះក៏អនុវត្តចំពោះរបាយការណ៍ហិរញ្ញវត្ថុនិមួយៗផងដែរ។

ឃ៣៧ កថាខណ្ឌ១៩ត្រូវបានកែប្រែដូចខាងក្រោមៈ

១៩ ការលាតត្រដាងព័ត៌មានដែលបានតម្រូវដោយ កថាខណ្ឌ ១៨ ត្រូវធ្វើឡើងដាច់ដោយឡែកពីគ្នាសម្រាប់ប្រភេទដូចខាងក្រោមៈ

(ក) ក្រុមហ៊ុនមេ,

(ខ) អង្គភាពដែលមានអភិបាលភាពរួមគ្នា ឬដែលមានឥទ្ធិពលខ្លាំងលើអង្គភាព,

(គ) ក្រុមហ៊ុនបុត្រសម្ពន្ធ័,......

ឃ៣៨ កថាខណ្ឌ២៥ត្រូវបានកែប្រែដូចខាងក្រោមៈ

**២៥ អង្គភាពរាយការណ៍ដែលត្រូវបានលើកលែងពីការ តម្រូវឱ្យមានការលាតត្រដាងព័ត៌មាននៃកថាខណ្ឌ១៨ ទាក់ទងនឹងប្រតិបត្តិការរបស់ភាគីទីបីនិងសមតុល្យនៅជំពាក់ រួមមានទាំងកាតព្វកិច្ចបំណុលផងដែរ ជាមួយនឹងៈ**

**(ក)រដ្ឋាភិបាលដែលមានអភិបាលភាព ឬអភិបាលភាពរួមលើ ឬមានឥទ្ធិពលសំខាន់លើអង្គភាពរាយការណ៍, និង**

**(ខ)ភាគីមួយផ្សេងទៀតដែលជាភាគិពាក់ពន្ធ័ដោយសារតែរដ្ឋាភិបាលដូចគ្នាមានអភិបាលភាព, ឬអភិបាលភាពរួមលើ, មាន**

**ឥទ្ធិពលសំខាន់លើ ទាំងអង្គភាពរាយការណ៍ និងអង្គភាពផ្សេងទៀត។**

ឃ៣៩ កថាខណ្ឌ២៨ក ត្រូវបានបន្ថែមដូចខាងក្រោម៖

២៨ក ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និងស្តង់ដារបាយ-ការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួម,* បានចេញផ្សាយនៅ ខែឧសភា ឆ្នាំ២០១១, បានកែប្រែកថាខណ្ឌ៣, កថាខណ្ឌ៩, កថាខណ្ឌ១១(ក), កថាខណ្ឌ១៥, កថាខណ្ឌ១៩(ខ) និងកថាខណ្ឌ១៩(ង), និងកថាខណ្ឌ២៥។ អង្គភាពត្រូវអនុវត្តកំណែប្រែនោះនៅពេលអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ និង ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

## ស្តង់ដាគណនេយ្យអន្តរជាតិ៣២ *ឧបករណ៍ហិរញ្ញវត្ថុ៖ការដាក់បង្ហាញ*

ឃ៤០ កថាខណ្ឌ៤(ក) ត្រូវបានកែប្រែដូចខាងក្រោម៖

៤ **ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះត្រូវអនុវត្តដោយគ្រប់អង្គភាពទាំងអស់ចំពោះគ្រប់ប្រភេទឧបករណ៍ហិរញ្ញវត្ថុលើកលែងតែ៖**

**(ក)បណ្តាភាគកម្មនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ, ក្រុមហ៊ុនញាតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុនដែលត្រូវបានកំណត់ដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០*<u>របាយការណ៍ហិរញ្ញវត្ថុសមាស,</u>* ស្តង់ដាគណនេយ្យអន្តរជាតិ២៧*~~របាយការណ៍ហិរញ្ញវត្ថុសមាសនិង~~ របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក,* ឬ ស្តង់ដាគណនេយ្យអន្តរជាតិ២៨*~~ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិ~~***

~~*សម្ពន្ធ័និងក្រុមហ៊ុនរួមទុន,*~~

~~ឬស្តង់ដាគណនេយ្យអន្តរជាតិ៣១ *ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន។*~~ **ទោះជាយ៉ាងណា នៅក្នុងករណីខ្លះ ស្តង់ដាគណនេយ្យអន្តរជាតិ២៧, ឬ ស្តង់ដាគណនេយ្យអន្តរជាតិ២៨,** ~~ឬស្តង់ដាគណនេយ្យអន្តរជាតិ ៣១~~

**អនុញ្ញាតិឲ្យអង្គភាពកំណត់ភាគកម្មនៅក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ័, ក្រុមហ៊ុនញាតិសម្ពន្ធ័ ឬក្រុមរួមទុន ដោយប្រើ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩, នៅក្នុងករណីទាំងនោះ.......**

ឃ៤១ កថាខណ្ឌ ៩៧ឈ ត្រូវបានបន្ថែមដូចខាងក្រោមៈ

៩៧ឈ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១ *កិច្ចព្រមព្រៀងរួម,* បានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១,បានកែប្រែ កថាខណ្ឌ៤(ក)និង កថាខណ្ឌ កឆ២៩។ អង្គភាពត្រូវអនុវត្តកំណែប្រែនោះនៅពេលអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ និង ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

## ស្តង់ដាគណនេយ្យអន្តរជាតិ៣៣ ចំណេញក្នុងមួយភាគហ៊ុន

ឃ៤២ កថាខណ្ឌ៤០និងកថាខណ្ឌ ក១១ ត្រូវបានកែប្រែ ហើយកថាខណ្ឌ ៧៤ខ ត្រូវបានបន្ថែម ដូចខាងក្រោមៈ

៤០ ក្រុមហ៊ុនបុត្រសម្ពន្ធ័, ក្រុមហ៊ុនរួមទុន ឬ ក្រុមហ៊ុន ញាតិសម្ពន្ធ័អាចបោះផ្សាយបណ្ណ័ភាគហ៊ុនធម្មតាទៅបណ្តាភាគីនានាដែលមិនមែនជាក្រុមហ៊ុនមេ,

~~អ្នកវិនិយោគរួមទុន~~ឬអ្នកវិនិយោគដែលមានអភិបាលភាព រួមលើ ឬ មានឥទ្ធិពលខ្លាំងលើក្រុមហ៊ុនរងការវិនិយោគ ដែលបណ្ណ័ភាគហ៊ុនទាំងនោះអាចបំប្លែងទៅជា បណ្ណ័ភាគហ៊ុនធម្មតារបស់ ក្រុមហ៊ុនញាតិសម្ពន្ធ៍ ក្រុមហ៊ុនរួមទុន ឬក្រុមហ៊ុនញាតិសម្ពន្ធ៍, ឬ ជាបណ្ណ័ភាគហ៊ុនធម្មតារបស់ក្រុមហ៊ុនមេ, ឬអ្នកវិនិយោគដែលមានអភិបាលភាពរួម ឬមានឥទ្ធិពលខ្លាំងលើ (អង្គភាពរាយការណ៍)លើ ក្រុមហ៊ុនរងការវិនិយោគ ~~អ្នកវិនិយោគរួមទុន ឬអ្នកវិនិយោគ~~។ ប្រសិនបើ បណ្ណ័ ភាគហ៊ុនធម្មតាទាំងនេះរបស់ ក្រុមហ៊ុនញាតិសម្ពន្ធ៍ ក្រុមហ៊ុនរួមទុន ឬ ក្រុមហ៊ុនញាតិសម្ពន្ធ៍ មាន ផលប៉ះពាល់នៃភាពកំសោយ(dilutive effect) លើចំណេញធម្មតាក្នុងមួយបណ្ណ័ភាគហ៊ុនរបស់អង្គភាព រាយការណ៍, ពួកវាត្រូវបានបញ្ចូលទៅក្នុងការគណនាចំណេញដែលបានបន្ថយ ក្នុងមួយបណ្ណ័ភាគហ៊ុន (diluted earning per share)។

ក១១ បណ្ណភាគហ៊ុនធម្មតាថ្មីរបស់ក្រុមហ៊ុនញាតិសម្ពន្ធ៍ ក្រុមហ៊ុនរួមទុន ឬ ក្រុមហ៊ុនញាតិសម្ពន្ធ៍ អាចបំប្លែងទៅជាបណ្ណភាគហ៊ុនធម្មតា របស់បណ្ណភាគហ៊ុនធម្មតារបស់ក្រុមហ៊ុនបុត្រសម្ពន្ធ៍ ក្រុមហ៊ុន រួមទុន ឬក្រុមហ៊ុនញាតិសម្ព័ន្ធ, ឬបណ្ណ័ភាគហ៊ុនធម្មតា របស់ ក្រុមហ៊ុនមេ, ឬវិនិយោគិនដែលមានអភិបាលភាពរួមលើ ឬ មានឥទ្ធិពលខ្លាំងលើ (អង្គភាពរាយការណ៍) ក្រុមហ៊ុនរងការ វិនិយោគ, អ្នកវិនិយោគរួមទុន វិនិយោគិនត្រូវបានដាក់បញ្ចូល

ទៅក្នុងការគណនាចំណេញ ដែលបានបន្ថយ ក្នុងមួយបណ្ណ័ភាគហ៊ុន (diluted earning per share)។

៧៤ខ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួម*, បានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១, បានកែប្រែ កថាខណ្ឌ៤ កថាខណ្ឌ៤០ និងកថាខណ្ឌ ក១១។ អង្គភាពត្រូវអនុវត្តកំណែប្រែនោះនៅពេលអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

## ស្តង់ដាគណនេយ្យអន្តរជាតិ៣៦ *ការថយចុះតម្លៃនៃទ្រព្យសកម្ម*

ឃ៤៣ កថាខណ្ឌ១៤០ជ ត្រូវបានបន្ថែមដូចខាងក្រោម:

១៤០ជ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ និង ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួម*, បានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១, បានកែប្រែកថាខណ្ឌ៤, ចំណងជើងខាងលើកថាខណ្ឌ១២(ជ) និងកថាខណ្ឌ១២(ជ)។ អង្គភាព ត្រូវអនុវត្តកំណែប្រែនោះ នៅពេលអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១។

## ស្តង់ដាគណនេយ្យអន្តរជាតិ៣៨ *ទ្រព្យសកម្មអរូបិយ៍*

ឃ៤៤ កថាខណ្ឌ៣(ង)ត្រូវបានកែប្រែដូចខាងក្រោម:

៣ ប្រសិនបើ ស្តង់ដារផ្សេងទៀតដាក់បញ្ញត្តិអំពីការកត់ត្រាប្រភេទនៃទ្រព្យសកម្មអរូបិយ,អង្គភាពអនុវត្ត ស្តង់ដារនោះជំនួសស្តង់ដារនេះ។ឧទាហរណ៍ ស្តង់ដានេះមិនអនុវត្តចំពោះ :

(ក).......

(ខ) ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកំណត់អត្ថន័យនៅក្នុងស្តង់ដាគណនេយ្យអន្តរជាតិ៣២។ការទទួលស្គាល់និងការវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុខ្លះត្រូវបានគ្រប់ដណ្តប់នៅក្នុងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០*<u>របាយការណ៍ហិរញ្ញវត្ថុសមាស</u>*, ស្តង់ដាគណនេយ្យអន្តរជាតិ២៧ ~~*របាយការណ៍ហិរញ្ញវត្ថុសមាស*~~*និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក*, ឬ ស្តង់ដាគណនេយ្យអន្តរជាតិ២៨ ~~*ការវិនិយោគនៅក្នុងក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ*~~*<u>និងក្រុមហ៊ុនរួមទុន</u>*, ~~ឬស្តង់ដាគណនេយ្យអន្តរជាតិ៣១ *ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន*។~~

(ច).........

ឃ៤៥ កថាខណ្ឌ ១៣០ច ត្រូវបានបន្ថែមដូចខាងក្រោម៖

១៣០ច ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួម*, បានចេញផ្សាយ នៅខែឧសភា ឆ្នាំ២០១១, បានកែប្រែកថាខណ្ឌ ៣(ង)។អង្គភាពត្រូវអនុវត្តកំណែប្រែនោះនៅពេលអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ និងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

ឃ៤៦ កថាខណ្ឌ២(ក) ត្រូវបានបន្ថែមដូចខាងក្រោមៈ

២ ស្តង់ដារ នេះត្រូវតែអនុវត្តដោយគ្រប់អង្គភាពទាំងអស់ ចំពោះគ្រប់ប្រភេទនៃឧបករណ៍ហិរញ្ញវត្ថុ លើកលែងតែៈ

**(ក) បណ្តាភាគកម្មនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ, ក្រុមហ៊ុនញាតិសម្ពន្ធ័ ឬ ក្រុមហ៊ុនរួមទុនដែលត្រូវបានកំណត់ ដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០*របាយការណ៍ហិរញ្ញវត្ថុសមាស*, ស្តង់ដាគណនេយ្យអន្តរជាតិ២៧~~*របាយការណ៍ហិរញ្ញវត្ថុសមាសនិង*~~ *របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក*, ឬ ស្តង់ដាគណនេយ្យអន្តរជាតិ២៨~~*ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ពន្ធ័និងក្រុមហ៊ុនរួមទុន*~~, ~~និងស្តង់ដាគណនេយ្យអន្តរជាតិ៣១ *ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន*~~ ។ ទោះជាយ៉ាងណា អង្គភាពត្រូវអនុវត្តស្តង់ដានេះចំពោះភាគកម្មនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ, ក្រុមហ៊ុនញាតិសម្ពន្ធ័ ឬ ក្រុមរួមទុន ដោយយោងតាមស្តង់ដារគណនេយ្យអន្តរជាតិ២៧, ឬ ស្តង់ដារគណនេយ្យអន្តរជាតិ២៨ ឬ ~~ស្តង់ដាគណនេយ្យ៣១~~ ដែលត្រូវបានកំណត់នៅក្រោមស្តង់ដារនេះ.....**

ឃ៤៧ កថាខណ្ឌ កង៣និង កថាខណ្ឌ កង៤ថ(ក) ត្រូវបានកែប្រែដូចខាងក្រោមៈ

កង៣ ជូនកាល អង្គភាពមួយធ្វើអ្វីមួយដែលខ្លួនគិតថា ជា“ ការវិនិយោគជាយុទ្ធសាស្ត្រ” នៅក្នុងឧបករណ៍ហិរញ្ញវត្ថុជាមូលធនផ្ទាល់ ដែលបានបោះផ្សាយដោយអង្គភាពមួយ ផ្សេងទៀតក្នុងគោលបំណង នៃការបង្កើត និងការរក្សាទំនាក់ទំនងប្រតិបត្តិការរយៈពេលវែងជាមួយអង្គភាព ដែលមានការវិនិយោគនៅជាមួយ។វិនិយោគិនឬអ្នកវិនិយោគរួមទុន ប្រើស្តង់ដាគណនេយ្យអន្តរជាតិ២៨ដើម្បីកំណត់ថាតើវិធីសាស្ត្រមូលធនផ្ទាល់មានភាពសមរម្យសម្រាប់ការវិនិយោគបែបនោះឬយ៉ាងណា។~~ស្រដៀងគ្នាអង្គភាពវិនិយោគប្រើ ស្តង់ដាគណនេយ្យអន្តរជាតិ៣១ដើម្បីកំណត់ថាតើ ការធ្វើសមាសជាផ្នែកឬវិធីសាស្ត្របូលធនផ្ទាល់ មានភាពសបរប្បសប្រាប់ការវិនិយោគបែបនេះឬយ៉ាងណា~~។ ប្រសិនបើ ~~គ្មាន~~វិធីសាស្ត្រមូលធនផ្ទាល់ ~~ឬ គ្មានការធ្វើសមាសជាផ្នែក~~ មិនសមស្រប, អង្គភាពអនុវត្តស្តង់ដានេះចំពោះការវិនិយោគជាយុទ្ធសាស្ត្រនោះ។

កង ៤៥(ក)អង្គភាពគឺជាអង្គភាពដាក់ទុនវិនិយោគមានហានិភ័យខ្ពស់, មូកនិធិអញ្ញមញ្ញ, បរធនបាល ឬអង្គភាពដែលស្រដៀងគ្នា ដែលអាជីវកម្មរបស់ខ្លួនកំពុងវិនិយោគនៅក្នុងទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងគោលបំណង យកចំណេញពីផលចំណេញសរុបនៅក្នុងទម្រង់នៃភាគកម្មឬភាគលាភ

និងបម្រែបម្រួលតម្លៃសមស្រប។
ស្តង់ដាគណនេយ្យអន្តរជាតិ២៨
~~និងស្តង់ដាគណនេយ្យអន្តរជាតិ៣១~~
អនុញ្ញាតិឲ្យការវិនិយោគបែប
នោះ~~ត្រូវបានដកចេញពីក្របខណ្ឌដែលបានផ្តល់ឲ្យពួកវាត្រូវបាន~~
វាស់វែងតាមតម្លៃសមស្របនាចុងការិយបរិច្ឆេទ
ដោយអនុលោមតាមស្តង់ដានេះ។
អង្គភាពអាចអនុវត្តគោលនយោបាយគណនេយ្យ
ដូចគ្នាចំពោះការវិនិយោគផ្សេងទៀតដែលបានគ្រប់គ្រងដោយផ្តែ
កលើមូលដ្ឋានផលចំណេញសរុប ប៉ុន្តែ
ដែលឥទ្ធិពលរបស់វាមិនគ្រប់គ្រាន់សម្រាប់ពួកវាឲ្យស្ថិតនៅក្នុង
ក្របខណ្ឌនៃស្តង់ដាគណនេយ្យអន្តរជាតិ២៨
~~ឬស្តង់ដាគណនេយ្យអន្តរជាតិ៣១~~។

ឃ៤៨ កថាខណ្ឌ ១០៣ប ត្រូវបានបន្ថែមដូចខាងក្រោមៈ

១០៣ប ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួម,* បានចេញផ្សាយ នៅខែឧសភា ឆ្នាំ២០១១, បានកែប្រែ កថាខណ្ឌ ២(ក), កថាខណ្ឌ១៥, កថាខណ្ឌ កង៣, កថាខណ្ឌ កង៣៦- កថាខណ្ឌ កង៣៨, និងកថាខណ្ឌ កង៤(ក)។អង្គភាពត្រូវអនុវត្តកំណែប្រែនោះនៅពេលអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១។

## IFRIC ៥ សិទ្ធិចំពោះភាគកម្មដែលកើតឡើងពីមូលធិនិ នៃការបញ្ឈប់បេសកម្ម, ការស្តារឡើងវិញ, និងការរៀបចំស្តាបរិស្ថាន

យ៤៩ កថាខណ្ឌ៨និងកថាខណ្ឌ៩ត្រូវបានកែប្រែដូចខាងក្រោម៖

៨ អ្នកចូលរួមទុនត្រូវកំណត់ថាតើខ្លួនមានអភិបាលភាព, ឬអភិបាលភាពរួមលើ ឬមានឥទ្ធិពលខ្លាំងលើ មូលនិធិដោយសំអាង ចំពោះស្តង់ដាគណនេយ្យអន្តរជាតិ២៧, <u>ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ និងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១ និង</u>ស្តង់ដាគណនេយ្យអន្តរជាតិ ២៨, ស្តង់ដាគណនេយ្យអន្តរជាតិ៣១និង SIC ១២។ ប្រសិនបើ វាធ្វើដូច្នោះ អ្នកចូលរួមទុនត្រូវគណនាភាគកម្មរបស់ខ្លួននៅក្នុងមូលនិធិ ដោយអនុលោមតាមស្តង់ដាទាំងនោះ។

៩ ប្រសិនបើ អ្នកចូលរួមទុនមិនមានអភិបាលភាព, ឬអភិបាលភាពរួមលើ ឬមានឥទ្ធិពលខ្លាំងលើមូលនិធិ, អ្នកចូលរួមទុន ត្រូវទទួលស្គាល់សិទ្ធិដើម្បីបានទទួលនូវការសងវិញពីមូលនិធិ ថាជាការសងវិញ ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិ៣៧។ ការសងវិញនេះត្រូវបានវាស់វែងតាមតម្លៃទាបនៃ៖

(ក)...........

យ៥០ កថាខណ្ឌ១៤ខ ត្រូវបានបន្ថែមដូចខាងក្រោម៖

១៤ខ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួម,* បានចេញផ្សាយ នៅខែឧសភា ឆ្នាំ២០១១, បានកែប្រែ កថាខណ្ឌ ៨ និងកថាខណ្ឌ៩។ អង្គភាព ត្រូវអនុវត្តកំណែប្រែនោះ នៅពេល

អនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ និងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

## IFRIC ៩ ការវាយតម្លៃឡើងវិញ និស្សន្ទបង្កប់

យ៥១ [មិនអាចអនុវត្តបានចំពោះការតម្រូវ]

យ៥២ កថាខណ្ឌ១២ ត្រូវបានបន្ថែមដូចខាងក្រោម:

១២ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ បានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១ បានកែប្រែ កថាខណ្ឌ៥(គ)។អង្គភាពត្រូវអនុវត្តកំណែប្រែនោះនៅពេលអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

## IFRIC ១៦ ការទប់ស្កាត់ហានិភ័យនៃការវិនិយោគសុទ្ធនៅក្នុងប្រតិបត្តិការបរទេស

យ៥៣ និយមន័យលក្ខណៈចំពោះកថាខណ្ឌ២ ត្រូវបានកែប្រែដូចខាងក្រោម:

នេះគឺជាករណីសម្រាប់របាយការណ៍ហិរញ្ញវត្ថុសមាស, របាយការណ៍ហិរញ្ញវត្ថុ ដែលនៅក្នុងនោះការវិនិយោគនៅ ក្នុងក្រុមហ៊ុនញាតិសម្ពន្ធ ឬក្រុមហ៊ុនរួមទុន ត្រូវបានកំណត់ដោយប្រើវិធីសាស្រ្តមូលធនផ្ទាល់, របាយការណ៍ហិរញ្ញវត្ថុដែលនៅក្នុងនោះភាគកម្មរបស់អ្នកចូលរួមទុននៅក្នុងក្រុមហ៊ុន រួមទុនត្រូវបានធ្វើសមាសជាផ្នែកៗ(ជាកម្មវត្ថុនៃការផ្លាស់ប្តូរនៅក្នុងសេចក្តីព្រាង៩ *កិច្ចព្រមព្រៀងរួម* ដែលបានបោះផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ នៅខែកញ្ញា ឆ្នាំ២០០៧) និងរបាយការណ៍ហិរញ្ញវត្ថុដែលរួមមាននៅក្នុងសាខា ឬ ប្រតិបត្តិការរួមដូចបានកំណត់នៅក្នុងង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១ *កិច្ចព្រមព្រៀងរួម*។

ក្រុមប្រឹក្សាជាតិគណនេយ្យ
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាស័យដ្ឋាន៖ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែល៖ info@naccambodia.gov.kh | គេហទំព័រ៖ www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្ដង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ